ហាមលក់

ក្រសួងអប់រំ យុវជន និងកីឡា

# គណិតវិទ្យា

កំរិតមូលដ្ឋាន

១១

# កំណែ



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ជំពូកទី1 ស្វ៊ីត

មេរៀនទី1 **ស្វ៊ីតចំនួនពិត**

## លំហាត់

1.សរសេរបីតួបន្ទាប់នៃស្វ៊ីតខាងក្រោម:

ក, 5,10,15,20,... ខ, 1,5,14,30,55,...

2.សរសេរតួនៃស្វ៊ីតរាប់អស់ខាងក្រោម:

ក, $a_n = \dfrac{(-1)^n}{n}$ ចំពោះ $1 \le n \le 8$

ខ, $b_n = (2)^{-n+2}$ ចំពោះ $1 \le n \le 5$

3.សរសេរបួនតួនៃស្វ៊ីតរាប់អស់ខាងក្រោម:

ក, $a_n = \dfrac{(-1)^{2n}}{n^2}$ ខ, $b_n = \dfrac{1}{n^2+n}$

គ, $c_n = (-1)^n (n-2)^2$ ឃ $d_n = (-1)^n 2^{n-1}$

4.កំណត់តួទី $n$ ចំពោះគ្រប់ $n \in \mathbb{N}$ នៃស្វ៊ីតខាងក្រោម:

ក, 5,7,9,11,13,... ខ, $-3,-1,1,3,5,...$

គ, 16,13,10,7,4,... ឃ, $\dfrac{3}{2},\dfrac{3}{5},\dfrac{4}{7},\dfrac{5}{9},...$

5.បង្ហាញថាស្វ៊ីត $(a_n)$ ដែល $a_n=\frac{1}{3+n}$ ជាស្វ៊ីតចុះ ។

6.បង្ហាញថាស្វ៊ីត $(b_n)$ ដែល $b_n=\frac{2n+1}{n+3}$ ជាស្វ៊ីតកើន ។

7.សិក្សាភាពម៉ូណូតូននៃស្វ៊ីតដែលកំណត់ដូចខាងក្រោម:

ក, ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n=\frac{1}{n}$ ខ, ស្វ៊ីត $(a_n)$ ដែល $a_n=n^2-4n-5$

គ, ស្វ៊ីត $(a_n)\geq 4$ ដែល $a_n=n-4\ell n(n)$ ឃ, ស្វ៊ីត $a_n$ ដែល $a_{n+1}=a_n^2$ និង $a_0=2$

8.បង្ហាញថាស្វ៊ីត $(a_n)$ ដែល $a_n=\sqrt{n^2+1-n}$ ជាស្វ៊ីតទាល់ ។

9.តើស្វ៊ីតខាងក្រោមជាស្វ៊ីតទាល់ឬទេ ?

ក,ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $(a_n)=\frac{n^3+2n^2-1}{n^2+n}$

ខ, ស្វ៊ីត $(b_n)_{n\in\mathbb{N}}$ ដែល $b_n=\frac{\pi}{n}$

គ, ស្វ៊ីត $(c_n)$ ដែល $c_n=\frac{n+1}{n+3}$

10.តើបណ្តាស្វ៊ីតខាងក្រោមមួយណាជាស្វ៊ីតទាល់លើ ទាល់ក្រោម និងជាស្វ៊ីតទាល់ ? រួចរកគោលនៃស្វ៊ីតនីមួយៗ ។

ក, $a_n = \dfrac{n^3+2n^2-1}{n^2+n}, n \geq 1$

ខ, $a_n = \dfrac{e^n}{n^2+3n-4}, n \geq 2$

11.គេមានស្វ៊ីត $(a_n)$ ដែល $n$ ជាចំនួនគត់ហើយ $a_0 = 0$ និង

$a_{n+1} = a_n^2 + a_n + 1$

ក,បង្ហាញថាស្វ៊ីត $(a_n)$ ដែល $n$ ជាចំនួនគត់ ជាស្វ៊ីតកើន ។

ខ, បង្ហាញថាចំពោះគ្រប់ $n, a_n \geq n$ ។

## ដំណោះស្រាយ

1.សរសេរបីតួបន្ទាប់នៃស្វ៊ីតខាងក្រោម៖

ក, 5,10,15,20,25,30,35,...

ខ, 1,5,14,30,55,...

2.សរសេរតួនៃស្វ៊ីតរាប់អស់ខាងក្រោម៖

ក, $a_n = \dfrac{(-1)^n}{n}$ ចំពោះ $1 \leq n \leq 8$ គេបាន៖

$a_1 = \dfrac{(-1)^1}{1} = -1$ , $a_2 = \dfrac{(-1)^2}{2} = \dfrac{1}{2}$, $a_3 = \dfrac{(-1)^3}{1} = \dfrac{1}{3}$,

$a_4 = \dfrac{(-1)^4}{4} = \dfrac{1}{4}$

$a_5=-\frac{1}{5}, a_6=\frac{1}{6}, a_7=-\frac{1}{7}, a_8=\frac{1}{8}$

ខ, $b_1=2^{-1+2}=2, b_2=2^{-2+2}=1, b_3=2^{-3+2}=\frac{1}{2}$

$b_4=2^{-4+2}=2^{-2}=\frac{1}{4}, b_5=2^{-5+2}=2^{-3}=\frac{1}{8}$ ។

3.សរសេរបួនតួនៃស្វ៊ីតរាប់អស់ខាងក្រោមៈ

ក, $a_n=\frac{(-1)^{2n}}{n^2}$ គេបានៈ

$$a_1=\frac{(-1)2}{1^2}=1, a_2=\frac{(-1)^4}{2^2}=\frac{1}{4}, a_3=\frac{(-1)^6}{3^2}=\frac{1}{9}$$

និង $b_4=\frac{(-1)^8}{2^4}=\frac{1}{16}$

ខ, $b_n=\frac{1}{n^2+n}, n\in\mathbb{N}^*$ គេបានៈ

$$b_1=\frac{1}{1^2+1}=\frac{1}{2}, b_2=\frac{1}{2^2+2}=\frac{1}{6}, b_3=\frac{1}{3^2+3}=\frac{1}{12},$$

$$b_4=\frac{1}{4^2+4}=\frac{1}{20}$$

គ, $c_n=(-1)^n(n-2)^2$ គេបានៈ

ាង $(V_n)$ ជាតួទី $n$ នៃស្វ៊ីតនេះ

គមាន:

$V_1 = -3 = 2\times1-5$

$V_2 = -1 = 2\times2-5$

$V_3 = 1 = 2\times3-5$

$V_4 = 3 = 2\times4-5$

$V_5 = 5 = 2\times5-5$

.........................

.........................

ចនេះ: $\boxed{V_n = 2n-5; n \geq 1}$

$16, 13, 10, 7, 4, \ldots$

ង $(W_n)$ ជាតួទី $n$ នៃស្វ៊ីតនេះគេបាន

$W_1 = 16 = -3\times1+19$

$W_2 = 13 = -3\times2+19$

$W_3 = 10 = -3\times3+19$

$W_4 = 7 = -3\times4+19$

$W_5 = 4 = -3\times5+19$

..............................

..............................

ដូចនេះ $\boxed{W_n = -3n + 19, n \geq 1}$

ឃ, $\frac{2}{3}, \frac{3}{5}, \frac{4}{7}, \frac{5}{9}, \ldots$

តាង $(T_n)$ ជាតួទី $n$ នៃស្វ៊ីតនេះ

គេមាន:

$$T_1 = \frac{2}{3} = \frac{1+1}{2\times1+1}$$

$$T_2 = \frac{3}{5} = \frac{2+1}{2\times2+1}$$

$$T_3 = \frac{4}{7} = \frac{3+1}{2\times3+1}$$

$$T_4 = \frac{5}{90} = \frac{4+1}{2\times4+1}$$

..............................

..............................

ដូចនេះ $\boxed{T_n = \frac{n+1}{2n+1}, n \geq 1}$

5.បង្ហាញថា $(a_n)$ ជាស្វ៊ីតចុះ

គេមាន: $a_n = \frac{1}{n+3} \Rightarrow a_{n+1} = \frac{1}{n+4}$

នោះគេបាន $a_{n+1}-a_n=\frac{1}{n+4}-\frac{1}{n+3}$

$$=\frac{n+3-n-4}{(n+4)(n+3)}=-\frac{1}{(n+4)(n+3)}<0, n\in\mathbb{N}$$

$$\Rightarrow a_{n+1}<a_n$$

ដូចនេះ $(a_n)$ ជាស្វីតចុះ

6.បង្ហាញថា $(b_n)$ ជាស្វីតកើន

គេមាន: $b_n=\frac{2n+1}{n+3}\Rightarrow b_{n+1}=\frac{2n+3}{n+4}$ គេបាន:

$$b_{n+1}-b_n=\frac{2n+3}{n+4}-\frac{2n+1}{n+3}$$

$$=\frac{(n+3)(2n+3)-(n+4)(2n+1)}{(n+4)(n+3)}$$

$$=\frac{2n^2+9n+9-2n^2-9n-4}{(n+4)(n+3)}$$

$$=\frac{5}{(n+4)(n+3)}>0, \forall n\in\mathbb{N}\Rightarrow b_{n+1}>b_n$$

ដូចនេះ $(b_n)$ ជាស្វីតកើន

7.សិក្សាភាពម៉ូណូតូននៃស្វីត

$c_0=(-1)^0(-2)^2=4$ , $c_1=-1(-1)^2=-1$ ,

$c_2=(-1)^2(2-2)^2=0, c_3=(-1)^3(3-2)^2=-1$

ឃ, $d_n=(-1)^n 2^{n-1}$ គេបាន:

$d_0=(-1)^0.2^{-1}=\frac{1}{2}, d_1=(-1)2^0=-1,$

$d_2=(-1)^2.2^{2-1}=2$ , $d_3=(-1)^3.2^{3-1}=-4$

4.ក, $5,7,9,11,13,\ldots$

តាង $(u_n)$ ជាស្ទីតតួទី $n$ នៃស្ទីតនេះ

គេមាន:

$u_1=5=2\times2+1$

$u_2=7=2\times3+1$

$u_3=9=2\times4+1$

$u_4=11=2\times5+1$

$u_5=13=2\times6+1$

..............................

..............................

តាមលំនាំគំរូនេះគេបាន $\boxed{u_n=2(n+1)+1\ , n\geq1}$

ខ, $-3,-1,1,3,5,\ldots$

ក, ស្វ៊ីត $(a_n)_{n\in\mathbb{N}^*}$ ដែល $a_n=\dfrac{1}{n}$

$\Rightarrow a_{n+1}=\dfrac{1}{n+1}$ គេបាន:

$$a_{n+1}-a_n=\frac{1}{n+1}-\frac{1}{n}=\frac{n-n-1}{n(n+1)}=-\frac{1}{n(n+1)}<0;$$

$\forall n\geq 1\Rightarrow a_{n+1}<a_n$

ដូចនេះ $(a_n)$ ជាស្វ៊ីតម៉ូណូតូន

ខ, $a_n=n^2-4n-5\Rightarrow a_{n+1}=(n+1)^2-4(n+1)-5$

$=n^2+2n+1-4n-4-5=n^2-2n-8$

គេបាន: $a_{n+1}-a_n=n^2-2n-8-n^2+4n+5$

$\Rightarrow a_{n+1}\geq a_n\ ;\forall n\in\mathbb{N}, n\geq 2$

ដូចនេះ $(a_n)$ ជាស្វ៊ីតម៉ូណូតូនចំពោះ $n\geq 2$

ឃ, ស្វ៊ីត $(a_n)$ ដែល $a_{n+1}=a_n^2$ និង $a_0=2$

គេបាន: $a_1=a_0^2=2^2=4$

$a_2=a_1^2=4^2=16$

$a_3=a_2^2=16^2=256$

..............................

$a_{n+1}=a_n^2$

គេសង្កតឃើញថា: $a_1 < a_2 < a_3 < a_4 < \ldots < a_n$

ដូចនេះ $(a_n)$ ជាស្វីតម៉ូណូតូន

8.បង្ហាញថា $(a_n)$ ជាស្វីតទាល់

គេមាន $a_n = \sqrt{n^2+1} - n$

$\forall n \in \mathbb{N}$ គេបាន $a_n > 0 \ (1)$

ម្យ៉ាងទៀត $\sqrt{n^2+1} - n \le 1, \forall n \in \mathbb{N} \ (2)$

តាម $(1)$ & $(2)$ គេបាន $0 < a_n \le 1$

ដូចនេះ $(a_n)$ ជាស្វីតទាល់

9.តើស្វីតខាងក្រោមជាស្វីតទាល់រឺ ទេ ?

ក, $a_n = \dfrac{n^3+2n^2-1}{n(n+1)}, \forall n \in \mathbb{N}^*$

$$= \frac{n^3+n^2+n^2-1}{n(n+1)} = \frac{n^2(n+1)+(n-1)(n+1)}{n(n+1)}$$

$$= \frac{(n+1)(n^2+n-1)}{n(n+1)} = \frac{n^2+n-1}{n} \ge 1, \forall n \in \mathbb{N}^*$$

$\Rightarrow a_n \ge 1, \forall n \in \mathbb{N}^*$

$\Rightarrow (a_n)$ ជាស្វីតទាល់ក្រោមតែ $(a_n)$ មិនទាល់លើ

ដូចនេះ $(a_n)$ ជាស្វ៊ីតមិនទាល់

ខ, $b_n = \frac{\pi}{n}, \forall n \in \mathbb{N}^*$

គេមាន $0 < \frac{\pi}{n} \leq \pi, \forall n \in \mathbb{N}^* \Rightarrow 0 < b_n \leq \pi, \forall n \in \mathbb{N}^*$

ដូចនេះ $(b_n)$ ជាស្វ៊ីតទាល់

គ, $c_n = \frac{n+1}{n+3}, \forall n \in \mathbb{N}$

$+\forall n \in \mathbb{N}$ គេបាន $c_0 \geq 0$ (1)

$+\frac{n+1}{n+3} = \frac{n+3-2}{n+3} = 1 - \frac{2}{n+3} \leq 1, \forall n \in \mathbb{N}$ (2)

តាម(1)&(2) គេបាន $0 \leq c_n \leq 1, \forall n \in \mathbb{N}$

**ដូចនេះ $(c_n)$ ជាស្វ៊ីតទាល់**

10.តើបណ្ដាស្វ៊ីតខាងក្រោមមួយណាជាស្វ៊ីតទាល់លើ ទាល់ក្រោម និងជាស្វ៊ីតទាល់ ? រួចរកគោលនៃស្វ៊ីតនីមួយៗ ។

ក, $a_n = \frac{n^3 + 2n^3 - 1}{n^2 + n}, \forall \in \mathbb{N}^*$

តាមលំហាត់លេខ (៩) សំនួរ (ក) គេបាន: $a_n \geq 1, \forall n \in \mathbb{N}^*$

គេបាន $(a_n)$ ជាស្វ៊ីតទាល់ក្រោមហើយចំនួនទាល់ក្រោមគឺ $N = 1$ ។

ខ, $a_n = \frac{e^n}{n^2+3n-4}, n \geq 2$

+$\forall n \geq 2$ គេបាន $\frac{e^n}{n^2+3n-4} \geq \frac{e^2}{6} \Rightarrow a_n \geq \frac{e}{6}$

ដូចនេះ $(a_n)$

ជាស៊ីតទាល់ក្រោមហើយចំនួនទាល់ក្រោមគឺ $\frac{e^2}{6}$ ។

11.ក,បង្ហាញថា $(a_n)$ ជាស៊ីតកើន

គេមាន $a_{n+1} = a_n^2 + a_n + 1$ និង $a_0 = 1$

គេបាន $a_1 = a_0^2 + a_0 + 1 = 1+1+1 = 3$

$a_2 = a_1^2 + a_1 + 1 = 3^2 + 3 + 1 = 13$

$a_3 = a_2^2 + a_2 + 1 = 13^2 + 13 + 1 = 183$

$a_4 = a_3^2 + a_3 + 1 = 183^2 + 183 + 1 = 33673$

.............................................................................

.............................................................................

ដូចនេះ $(a_n)$ ជាស៊ីតកើន

ខ,បង្ហាញថាចំពោះគ្រប់ $n, a_n \geq n$

យើងនឹងស្រាយបញ្ជាក់តាមវិធារកំណើន

+ចំពោះ $n=0$ គេបាន $a_0 = 1 > 0$ ពិត

+ឧបមាថាពិតដល់ $n=k$ គឺ $a_k \geq k$ ពិត

+យើងនឹងស្រាយថាពិតដល់ $n=k+1$

គេមាន: $a_k \geq k \Leftrightarrow a_k + a_k + 1 \geq a_k^2 + k + 1 \geq k$

$\Leftrightarrow a_{k+1} \geq k$ ពិត

ដូចនេះ: $a_n \geq n, \forall n \in \mathbb{N}$

## មេរៀនទី2 ស្វ៊ីតនព្វន្ត

លំហាត់

1.សរសេររូបមន្តតួទី $n$ នៃស្វ៊ីតនព្វន្តខាងក្រោម:

ក, 4, 15, 26, 37,... ខ, 5, 1, −3, −7, −11,...

គ, −2, −9, −16, −23,.... ឃ, 7, 12, 17, 22, 27,...

2.សរសេរប្រាំតួដំបូងនៃស្វ៊ីតនព្វន្តដែលកំណត់ដោយតួ:

ក, $U_1 = 3$ , $U_2 = 10$ ខ, $U_n = -7 + 3n$

3.គេមានស្វ៊ីតនព្វន្ត −8, −3, 2, 7,... ។

ក,គណនា $U_{17}$ និង $U_{43}$

ខ,តើតួទីប៉ុន្មាននៃស្វ៊ីតស្មើនឹង 322 ។

4.កំណត់ចំនួនតួនៃស្វ៊ីតនព្វន្តខាងក្រោម:

ក, 18, 13, 8, ..., −102 ខ, −9, −4, 1, ..., 171

5.ក្នុងចំណោមស្វ៊ីតខាងក្រោម តើស្វ៊ីតមួយណាជាស្វ៊ីតនព្វន្ត ?

ក, $U_n = 13 + 6(n-1)$

ខ, $U_0 = 3, U_{n+1} = U_n - \frac{1}{4}U_n$

6.គេឲ្យ $(U_n)$ ជាស្វ៊ីតនព្វន្ត បើដឹងថា

ក, $U_{35} = 9$ , $U_{45} = 17$ ។ គណនា $U_{40}$ ។

ខ, $U_7 = \frac{7}{2}$ , $U_{13} = \frac{13}{2}$ ។ គណនា $U_0$ ។

គ, $U_2 = -12$ , $U_{12} = 18$ ។ គណនា $U_1$ , $d$ និង $U_0$ ។

7.គេឲ្យស្វ៊ីនព្វន្ត 2, 7, 12, ... និងស្វ៊ីតនព្វន្ត 2, 5, 8, ... ។

តើក្នុងចំណោម 121 តួនៃស្វ៊ីតទាំងពីរនេះមានប៉ុន្មានតួ

ដែលលមានតម្លៃស្មើៗគ្នា ?

8.បង្ហាញថាស្វ៊ីត $(U_n)$ ដែលមានតួទី $n$ កំណត់ដោយ

$U_n = \frac{2n+3}{4}$ ជាស្វ៊ីតនព្វន្តកើន ។

9.គេឲ្យប្រាំចំនួនជាស្វ៊ីតនព្វន្ត ។

គណនាចំនួនទាំងនោះបើគេដឹងថាផលបូកវាស្មើនឹង 125

ហើយផលបូកពីរតួដំបូងស្មើនឹង 38 ។

10.បើផលបូក9តួដំបូងនៃស្វ៊ីតនព្វន្តស្មើនឹង162ហើយផលបូក

12 តួដំបូងនៃស្វ៊ីតស្មើនឹង 288 ។ គណនាផលបូក 30

តួដំបូងនៃស្វីតនព្វន្ត ។

11.រកបីចំនួនតគ្នាជាស្វ៊ីតបព្វន្តដោយដឹងថាផលបូកលនៃបីចំនួននេះស្មើនឹង 36 និងផលគុណវាស្មើនឹង 1428 ។

12.គណនាផលបូកស្វ៊ីតនព្វន្តខាងក្រោមៈ

ក, $2+4+6+...+146$

ខ, $100+95+90+85+...-20$

គ, $-193-189-185-...-21-17$

ឃ, $5\frac{1}{4}+4\frac{1}{2}+3\frac{3}{4}+...-3$ ។

13.អ្នកជិះកង់ម្នាក់ធ្វើដំណើរតាមផ្លូវ $A$ បានចម្ងាយ15 គីឡូម៉ែត្រក្នុង 1 ថ្ងៃ ។ប្រាំបីថ្ងៃក្រោយមក ទើបអ្នកជិះទីពីរចាប់ផ្តើមធ្វើដំណើរតាមផ្លូវ $A$ ដូចគ្នាដោថ្ងៃទីមួយ គាត់ជិះកង់បានបម្ងាយ 14 ឡូម៉ែត្រក្នុង 1 ថ្ងៃ ហើយថ្ងៃបន្តបន្ទាប់មកទៀតគាត់ត្រូវជិះកើនបានចម្ងាយ 2 គីឡូម៉ែត្រក្នុង 1 ថ្ងៃជារៀងរាល់ថ្ងៃ ដើម្បីអោយទាន់អ្នកជិះកង់ទីមួយ $A$ ។ តើអ្នកជិះកង់ទីពីរត្រូវចំណាយរយៈពេលអស់ប៉ុន្មានថ្ងៃ ដើម្បីអោយទៅទាន់អ្នកជិះកង់ទីមួយ ?

14.សាលប្រជុំមួយរាងចតុកោណព្នាយ ហើយតាមជ្រុងទ្រេតនៃសាលប្រជុំនោះ គេរៀបកៅអីជា 15 ជួរដែលជួរមុខគេបង្អស់

រៀបបាន 25 កៅអី ហើយជួរទីពីររៀបបាន27កៅអី ជួរទីបីរៀបបាន29កៅអី ។ គេរៀបកៅអីតាមលំនាំខាងលើរហូតដល់ជួរខាងក្រោយ។

គណនាកៅអីសម្រាប់អង្គុយទាំងអស់ដែលមានក្នុងសាលប្រជុំ ។

<u>ដំណោះស្រាយ</u>

1.សរសេររូបមន្តតួទី $n$ នៃស្វីតនព្វន្តខាងក្រោម:

តាមរូបមន្ត: $U_n = U_1 + (n-1)d$

ក, $4, 15, 26, 37, \ldots$ គេបាន $u_1 = 4$ និង

$d = u_2 - u_1 = 15 - 4 = 11$

ដូចនេះ: $U_n = 4 + (n-1).11$

ខ, $5, 1, -3, -7, -11, \ldots$ គេបាន: $u_1 = 5, u_2 = 1$ និង

$d = u_2 - u_1 = 1 - 5 = -4$

ដូចនេះ: $U_n = 5 + (n-1)(-4) = -4n + 9$

គ, $-2, -9, -16, -23, \ldots$ គេបាន $u_1 = -2, u_2 = -9$ និង

$d = u_2 - u_1 = -9 - (-2) = -9 + 2 = -7$

$\Rightarrow U_n = -2 + (n-1)(-7)$

ដូចនេះ: $U_n = -7n + 5$

ឃ, $7, 12, 17, 22, 27, \ldots$ គេបាន $u_1 = 7, u_2 = 12$ និង

$d = u_2 - u_1 = 12 - 7 = 5 \Rightarrow U_n = 7 + (n-1).5$

ដូចនេះ: $U_n = 5n + 2$

2.សរសេរប្រាំតួដំបូងនៃស្វ៊ីតនព្វន្តដែលកំណត់ដោយតួ:

ក, $u_1 = 3, u_2 = 10$ ដោយផលសងរួម

$d = u_2 - u_1 = 10 - 3 = 7$

គេបាន ប្រាំតួដំបូងនៃស្វ៊ីត $(U_n)$ គឺ:

$u_1 = 3, u_2 = 10, u_3 = 17, u_4 = 24$ និង $u_5 = 31$

ខ, $U_n = -7 + 3n \Rightarrow u_1 = -7 + 3 = -4$

$u_2 = -7 + 3\times2 = -1, u_3 = -7 + 3\times3 = 2,$

$u_4 = -7 + 3\times4 = 5, u_5 = -7 + 3\times5 = 8$

ដូចនេះ: ប្រាំតួដំបូងនៃស្វ៊ីតគឺ $(U_n)$ គឺ $-4, -1, 2, 5, 8$

3.គេមានស្វ៊ីតនព្វន្ត $-8, -3, 2, 7, \ldots$

ក,គណនា $U_{17}$ និង $U_{43}$

គេមាន $u_1 = -8, u_2 = -3$ និង $d = u_2 - u_1 = -3 + 8 = 5$

ដោយប្រើរូបមន្ត $U_n = u_1 + (n-1)d$ គេបាន

$U_{17} = -8 + (17-1).5 = -8 + 80 = 72$ ហើយ

$U_{43} = -8 + (43-1).5 = -8 + 210 = 202$

ដូចនេះ: $U_{17} = 72$ និង $U_{43} = 202$

ខ,តើតួទីប៉ុន្មាននៃស្វ៊ីតស្មើនឹង 322 ?

តាមរូបមន្ត $U_n = u_1 + (n-1)d$

$\Leftrightarrow 322 = -8 + (n-1).5 \Leftrightarrow 322 = 5n - 13$

$\Leftrightarrow 5n = 335 \Leftrightarrow n = \frac{335}{5} = 67$

ដូចនេះ: 322 ត្រូវនឹងតួទី 67 រឺ $U_{67} = 322$

4.កំណត់ចំនួនតួនៃស្វ៊ីតនព្វន្តខាងក្រោម:

ក, $18, 13, 8, \ldots, -102$

គេមាន $u_1 = 18, u_2 = 13, u_n = -102$ និង

$d = u_2 - u_1 = 13 - 18 = -5$

តាមរូបមន្ត $U_n = u_1 + (n-1).d$ គេបាន:

$-102 = 18 + (n-1)(-5) \Leftrightarrow -102 = -5n + 23$

$\Leftrightarrow 5n = 125$ នោះ: $n = \frac{125}{5} = 25$

ដូចនេះ: ស្វ៊ីតនព្វន្តនេះមាន 25 តួ

ខ, $-9, -4, 1, \ldots, 171$

គេមាន $u_1 = -9, u_2 = -4, u_n = 171$ និង

$d = u_2 - u_1 = -4 + 9 = 5$

ដោយប្រើរូបមន្ត $U_n = u_1 + (n-1).d$ គេបាន:

$171 = -9 + (n-1).5 \Leftrightarrow 171 = 5n - 14$

$5n = 185$ នោះ $n = \frac{185}{5} = 37$

ដូចនេះ ស្វ៊ីតនព្វន្តមាន 37 តួ

5.ក្នុងចំណោមស្វ៊ីតខាងក្រោម ស្វ៊ីតណាជាស្វ៊ីតនព្វន្ត ?

ក, $U_n = 13 + 6(n-1)$ គេបាន $U_{n+1} = 13 + 6n$

$\Rightarrow U_{n+1} - U_n = 13 + 16n - 13 - 6n + 6 = 6$ ថេរ

ដូចនេះ $(U_n)$ ជាស្វ៊ីតនព្វន្ត

ខ,គេមាន $U_0 = 3$ និង $U_{n+1} = U_n - \frac{1}{4}U_n$ គេបាន

$u_1 = u_0 - \frac{1}{4}u_0 = 3 - \frac{3}{4} = \frac{9}{4}$

$, u_2 = u_1 - \frac{1}{4}u_1 = \frac{9}{4} - \frac{1}{4} \times \frac{9}{4} = \frac{27}{4}$

ដោយ $u_2 - u_1 = \frac{9}{2} \neq u_1 - u_0 = -\frac{3}{4}$ ។ ដូចនេះ $(U_n)$ មិនមែនជាស្វ៊ីតនព្វន្ត

7.ក,គណនា $U_{40}$

គេមាន $\begin{cases} U_{35} = 9 \\ U_{45} = 17 \end{cases}$

ដោយប្រើរូបមន្ត $U_n = U_1 + (n-1).d$ គេបាន:

$$-\begin{cases} u_1 + 34d = 9 \ (1) \\ u_1 + 44d = 17 \ (2) \end{cases}$$

$$10 = 8d \Rightarrow d = \frac{8}{10} = \frac{4}{5}$$

ពី (1) : $u_1 = 9 - 34d = 9 - \frac{34\times 4}{5} = \frac{45-136}{5} = -\frac{91}{5}$

ដូចនេះ: $U_{40} = 13$

ខ,គណនា $U_0$

គេមាន: $\begin{cases} u_7 = \frac{7}{2} \\ u_{13} = \frac{13}{2} \end{cases} \Rightarrow U_0 = \frac{0}{2} = 0$ ដូចនេះ: $U_0 = 0$

គ,គណនា $U_1, d$ និង $U_6$

គេមាន: $\begin{cases} u_2 = -12 \\ u_{12} = 18 \end{cases}$

ដោយប្រើរូបមន្ត $U_n = u_1 + (n-1).d$ គេបាន:

$$\begin{cases} u_1+(2-1)d=18 \\ u_1+(12-1)d=18 \end{cases} \Leftrightarrow -\begin{cases} u_1+d=-12 & (1) \\ u_1+11d=18 & (2) \end{cases}$$

$$0+10d=30 \Rightarrow d=\frac{30}{10}=3$$

ពី $(1): u_1=-12-d=-12-3=-15$ គេបាន

$U_6=-15+(6-1).3=-15+15=0$

ដូចនេះ: $u_1=1, d=3$ និង $u_6=0$

តើក្នុងចំណោម 121

តួនៃស្វ៊ីតទាំងពីរនេះមានប៉ុន្មានតួដែលមានតម្លៃស្មើគ្នា

តាង $(a_n): 2,7,12,17,22,27,32,...$

$(b_n): 2,5,11,14,17,20,23,26,29,32,...$

គេបាន: $a_1=b_1=2$ , $a_4=b_6=17, a_7=b_{11}=32$

បើតាង $(c_n): 2,17,32,47,...$ គេបាន: $(c_n)$

ជាស្វ៊ីតនព្វន្តដែលមានផលសងរួម $d=15$

$\Rightarrow c_n=2+(n-1)15$ ដែល $c_n \le b_{121}$ (ព្រោះ $(b_n)$ មាន

ផលសងរួមតូចជាងផលសងរួមនៃស្វ៊ីត $(a_n)$ ដែល

$b_{121}=2+(121-1).3=362$

គេបាន: $c_n=2+(n-1)15 \le 362$

$$\Rightarrow n \le \frac{362+13}{15} = 25$$

**ដូចនេះ ស្វីតទាំងពីរនេះមាន 25 តួដូចៗគ្នា**

9.បង្ហាញថា $(U_n)$ ជាស្វីតនព្វន្តកើន

គេមាន $U_n = \frac{2n+3}{4} \Rightarrow U_{n+1} = \frac{2n+5}{4}$

គេបាន៖ $U_{n+1} - U_n = \frac{2n+5}{4} - \frac{2n+3}{4} = \frac{2}{4} = \frac{1}{2} > 0$

ដោយ $U_{n+1} - U_n > 0$ រឺ $U_{n+1} > U_n$

**ដូចនេះ $(U_n)$ ជាស្វីតនព្វន្តកើន**

10.គណនាចំនួនទាំងប្រាំនេះ

តាង $a_1, a_2, a_3, a_4, a_5$ ជាចំនួនត្រូវរក។ តាមបំរាប់ $a_1, a_2, a_3, a_4, a_5$ ជាស្វីតនព្វន្ត

គេបាន: $a_1 + a_5 = a_2 + a_4 = 2a_3 \quad (*)$

តែ $\begin{cases} a_1 + a_2 + a_3 + a_4 + a_5 = 125 \\ a_1 + a_2 = 38 \end{cases}$

$$\Leftrightarrow \begin{cases} (a_1 + a_5) + (a_2 + a_4) + a_3 = 125 \\ a_1 + a_2 = 38 \end{cases}$$

$$\Leftrightarrow \begin{cases} 2a_3 + 2a_3 + a_3 = 125 \\ a_1 + a_2 = 38 \end{cases} \Leftrightarrow \begin{cases} 5a_3 = 125 \\ a_1 + a_2 = 38 \end{cases}$$

$$\Leftrightarrow \begin{cases} a_3 = 25 \\ a_1 + a_2 = 38 \end{cases}$$

ពី (*) គេបាន: $\begin{cases} a_1 + a_5 = 25 \times 2 \\ a_1 + a_2 = 38 \end{cases}$

$$\Leftrightarrow - \begin{cases} 2a_1 + 4d = 50 & (1) \\ 2a_1 + d = 38 & (2) \end{cases}$$

$$0 + 3d = 12$$

$$\Rightarrow d = \frac{12}{3} = 4$$

ពី (1): $a_1 = \frac{50 - 4d}{2} = \frac{50 - 4 \times 4}{2} = 17$

**ដូចនេះ ចំនួនទាំង 5 នោះគឺ 17, 21, 25, 29, 33**

10.គណនាផលបូក 30 តួដំបូងនៃស្វ៊ីតនព្វន្ត

តាង $(U_n)$ ជាស្វ៊ីតតួទី $n$ នៃស្វ៊ីតនេះ

តាមបំរាប់គេបាន: $\begin{cases} s_9 = 162 \\ s_{12} = 288 \end{cases}$

$$\Leftrightarrow \begin{cases} \frac{9}{2}(u_1+u_9)=162\times\left(\frac{2}{9}\right) \\ \frac{12}{2}(u_1+u_{12})=288\times\left(\frac{2}{12}\right) \end{cases} \Leftrightarrow \begin{cases} u_1+u_9=18 \\ u_1+u_{12}=48 \end{cases}$$

$$\Leftrightarrow -\begin{cases} 2u_1+u_{12}=18 & (1) \\ 2u_1+11d=48 & (2) \end{cases}$$

$$0+3d=30 \Rightarrow d=10$$

ពី $(1): u_1=\frac{18-8d}{2}=\frac{18-8\times10}{2}=-31$

$\Rightarrow u_{30}=-31+29\times10=259$

គេបាន $S_{30}=\frac{30}{2}(-31+256)=15\times228=3420$

ដូចនេះ: $S_{30}=3420$

11.រកបីចំនួនតគ្នា

តាង $(a_n)$ ជាតួទី $n$ នៃស្វ៊ីតនព្វន្តនេះ

ដោយ $a_1,a_2,a_3$ ជាបីតួតគ្នានៃស្វ៊ីតនព្វន្ត គេបាន:

$a_1+a_2=2a_3 \quad (*)$

តាមបំរាប់គេបាន: $\begin{cases} a_1+a_2+a_3=36 \\ a_1\times a_2\times a_3=1428 \end{cases}$

$$\Leftrightarrow \begin{cases} 3a_2 = 36 \\ a_1 \times a_2 \times a_3 = 1428 \end{cases} \Leftrightarrow \begin{cases} a_2 = 12 \\ a_1 \times a_3 = 119 \quad (**) \end{cases}$$

តាម $(*)\&(**)$ គេបាន: $\begin{cases} a_1 + a_3 = 24 \\ a_1 \times a_3 = 119 \end{cases}$

$\Rightarrow a_1$ និង $a_3$ ជាឫសនៃសមីការ $x^2 - 24x + 119 = 0 \quad (3)$

ដោះស្រាយសមីការ $(3)$ គេបាន: $x_1 = 7, x_2 = 17$

ដូចនេះ បីចំនួននោះគឺ $7,12,17$ ឬ $17,12,7$

12.គណនាផលបូកស្ទីតនព្វន្តខាងក្រោម:

ក, $2+4+6+...+146 \Leftrightarrow 2(1+2+3+...+732)$

គេបាន $S_{73} = 2.\dfrac{73(73+1)}{2} = 73 \times 74 = 5402$

ដូចនេះ: $S_{73} = 5402$

ខ, $100+95+90+85+...-20$

តាង $a_n = 100+95+90+85+...-20$

$= (100+95+90+...+5) - (5+10+...+20) = b_n - c_n$

ដែល $b_n = 5(1+2+3+...+20)$

$= 5.\dfrac{20(20+1)}{2} = 50 \times 21 = 1050$

និង $c_n = 5(1+2+3+4) = 5\times 10 = 50$

$\Rightarrow a_n = 1050 - 50 = 1000$

ដូចនេះ: $100+95+90+\ldots-20=1000$

គ,គាង $(a_n) = -193, -189, -185, -\ldots, -21, 17$

ដោយ $(a_n)$ ជាស្វ៊ីតនព្វន្តដែលមានតួទី 1ស្មើនឹង $-193$

ហើយតួទី 45 ស្មើនឹង $-17$

គេបាន $S_{45} = \frac{45}{2}(-193-17) = \frac{45}{2}(-210) = -4725$

ដូចនេះ: $-193-198-185-\ldots-21-17=-4725$

ឃ, $5\frac{1}{4}+4\frac{1}{2}+3\frac{3}{4}+\ldots-3$ ។

តាង $(b_n): 5\frac{1}{4}, 4\frac{1}{2}, 3\frac{3}{4}, \ldots, -3$

+កំណត់ចំនួនតួនៃស្វ៊ីត $(b_n)$

តាមរូបមន្ត $b_n = b_1 + (n-1).d$

ដែល $b_1 = 5\frac{1}{4} = \frac{21}{4}, b_n = -3$ ហើយ

$d = 4\frac{1}{2} - 5\frac{1}{4} = -\frac{3}{4}$ គេបាន:

$-3 = -\frac{21}{4} + (n-1)\left(-\frac{3}{4}\right) \Leftrightarrow -3 = -\frac{3n}{4} + \frac{24}{4}$

$\Leftrightarrow -12 = -3n + 24 \Leftrightarrow 3n = 36 \Rightarrow n = \frac{36}{3} = 12$

មានន័យថាស្ទីត $(b_n)$ មាន 12 តួ

$\Rightarrow S_{12} = \frac{12}{2}\left(\frac{21}{4} - 3\right) = 6.\frac{9}{4} = \frac{27}{2}$

ដូចនេះ $5\frac{1}{4} + 4\frac{1}{2} + 3\frac{3}{4} + \ldots - 3 = \frac{27}{2}$

13.រករយៈពេលដែលអ្នកជិះកង់ទី 2 អាចទៅទាន់អ្នកទី 1

តាង $x$ ជាចម្ងាយផ្លូវជួបគ្នា $(x > 0)$ ។តាង $t$ ជាចំនួនថ្ងៃជួបគ្នា $(t > 0)$

+ចម្ងាយផ្លូវរយៈពេល $t$ ថ្ងៃគឺ $15t$

+ចម្ងាយផ្លូវ 8 ថ្ងៃគឺ $16 \times 8 = 120$

-ចំពោះអ្នកជិះកង់ទី 1 ៖ $x = 120 + 15t$

-ចំពោះអ្នកជិះកង់ទី 2

តាមរូបមន្តផលបូកស្ទីតនព្វន្តដែលមាន $t$ តួដែលតួទី1 ស្មើ 14 និងផលសងរួម $d = 2$

គេបាន: $x = \frac{t}{2}\left[2 \times 14 + 2(t-1)\right] = t^2 + 13t$

ដើម្បីអោយអ្នកជិះកង់ទី 2 តាមទាន់អ្នកជិះកង់ទី 1 លុះត្រាតែ

$t^2+13t=15t+120$

$\Leftrightarrow t^2-2t-120=0$

$\Delta'=1+120=121=11^2>0\Rightarrow t_1=1+11=12$

$t_2=1-11=-10<0$ (មិនយក)

ដូចនេះក្នុងរយៈពេល12ថ្ងៃអ្នកជិះកង់ទី 2 ជិះទាន់អ្នកជិះកង់ទី 1

14.គណនាចំនួនកៅអីទាំងអស់

សរុបចំនួននៃកៅអីដែលគេអោយតាមជួរមុខ និងជួរបន្ទាប់គេសង្កេតឃើញថាវាជាលំដាប់ស្វ៊ីត នព្វន្តមួយគឺ $25,27,29,31,\ldots$ ដើម្បីរកចំនួនកៅអីដែលមាន 15 ជួរ គេត្រូវកំណត់តួទី 15 នៃស្វ៊ីត។ តាមរូបមន្តៈ

$U_{15}=\frac{15}{2}(25+53)=585$

ដូចនេះ កៅអីទាំងអស់មានចំនួន 585 កៅអី

## មេរៀនទី3 ស្វ៊ីតធរណីមាត្រ

### លំហាត់

1.កំណត់ផលធៀបរួមនៃស្វ៊ីតធរណីមាត្រ និងសរសេរបួនតួបន្ទាប់ទៀតនៃស្វ៊ីតនីមួយៗខាងក្រោមៈ

ក, 4, 20, 100, 500, ... ខ, $\sqrt{2}$, 2, $2\sqrt{2}$, 4, ...

2.គេមានស្វីតធរណីមាត្រ 2, 6, 18, 54,...

ក,គណនាតួទី 7

ខ,តើចំនួន 39366 ជាតួទីប៉ុន្មាននៃស្វីត ?

គ,គណនាផលបូក 15 តួដំបូងនៃស្វីតធរណីមាត្រ ?

3.កំណត់ចំនួនតួនៃស្វីតធរណីមាត្រខាងក្រោម:

ក, 1, 2, 4, 8, ..., 8192

ខ, 20, 10, 5, $\frac{5}{2}$, ..., $\frac{5}{256}$

4.បង្ហាញថាស្វីតខាងក្រោមជាស្វីតធរណីមាត្រដែលមានតួទី $n$ កំណត់ដោយ

ក, $U_n = 7\times(3)^{n-1}$ ខ, $U_{n+1} = \frac{1}{8}\times(4)^n$

5.គេឲ្យ $(U_n)$ ជាស្វីតធរណីមាត្រ បើគេដឹងថា:

ក, $U_3 = 18$ , $U_7 = 1458$ ។ គណនា $q$ និង $U_{10}$

ខ, $U_3 = 20$ , $U_6 = 1280$ ។ គណនា $q$ និង $U_1$

គ, $U_1 = 3$ , $S_3 = 21$ ។ គណនា $q$ និង $S_1$

6.គណនាផលបូកស្វីតធរណីមាត្រខាងក្រោម:

ក, $48+24+12+\ldots+\frac{8}{3}$ ខ, $\frac{1}{3}+1+3+\ldots+6561$ ។

គ, $9-6+4-...-\frac{128}{243}$

ឃ, $1-\frac{1}{2}+\frac{1}{3^2}+\frac{1}{2^3}+\frac{1}{3^4}-\frac{1}{2^5}+...-\frac{1}{2^{2n-1}}+\frac{1}{3^{2n}}$

7.គណនាផលបូកស្ទីតធរណីមាត្រអន្តនតួដែលមាន $U_2=-9$ និង $U_5=\frac{1}{3}$

8.គណនាផលធៀបរួបនៃស្ទីតធរណីមាត្រអន្តនតួដែលមាន $U_1=5$ និង $S_\infty=15$ ។

9.ផលបូកពីរតួដំបូងនៃស្ទីតធរណីមាត្រស្មើនឹង 9 និងផលបូកនៃស្ទីតធរណីមាត្រអន្តនតួស្មើនឹង 25 ។

គណនា $q$ និង $U_1$ បើផលធៀបរួម $q>0$

10.សរសេរជាចំនួនសនិទានដែលមានទម្រង់ $\frac{a}{b}$ នូវចំនួនទសភាគខួបខាងក្រោម

ក, $0.\overline{7}$ ខ, $2.\overline{34}$ គ, $0.\overline{452}$

## ដំណោះស្រាយ

1.កំណត់ផលធៀបរួមនៃស្ទីតធរណីមាត្រ និងសរសេរបួនតួបន្ទាប់ទៀតនៃស្ទីតនីមួយៗខាងក្រោម:

ក, 4, 20, 100, 500, ...

គេមាន $u_1 = 4, u_2 = 20$ គេបាន: $q = \frac{u_2}{u_2} = \frac{20}{4} = 5$

ហើយបួនតួបន្ទាប់នៃស្វ៊ីតនេះគឺ

$\boxed{2500, 12500, 62500, 312500}$

ខ, $\sqrt{2}$, 2, $2\sqrt{2}$, 4, ...

គេបាន $u_1 = \sqrt{2}, u_2 = 2$ នោះ $q = \frac{2}{\sqrt{2}} = \sqrt{2}$

ហើយបួនតួបន្ទាប់នៃស្វ៊ីតនេះគឺ $\boxed{4\sqrt{2}, 8, 8\sqrt{2}, 16}$

2.គេមានស្វ៊ីតធរណីមាត្រ 2, 6, 18, 54,... ។

ក,គណនាតួទី 7។ តាង $(U_n)$ ជាតួទី $n$ នៃស្វ៊ីតនេះដែល $n \geq 1$

គេបាន $u_1 = 2, u_2 = 6$ នោះ $q = \frac{u_2}{u_1} = \frac{6}{2} = 3$ និង

$U_7 = u_1.q^6 = 2 \times 3^6 = 1458$

ដូចនេះ: $\boxed{U_7 = 1458}$

ខ,តើចំនួន 39366 ជាតួទីប៉ុន្មាននៃស្វ៊ីត ?

តាមរូបមន្តតួទី $n$ នៃស្វ៊ីតធរណីមាត្រ $U_n = u_1.q^{n-1}$ គេបាន:

$39366 = 2.3^{n-1} \Leftrightarrow 3^{n-1} = 19683 \Leftrightarrow 3^{n-1} = 3^9 \Rightarrow n-1 = 9 \Leftrightarrow n = 8$

ដូចនេះ: 39366 តួទី 8 នៃស្វ៊ីត

គ,គណនាផលបូក 15 តួដំបូងនៃស្ទីតនេះ។ តាមរូបមន្ត

$$S_n = \frac{U_1(q^n - 1)}{q - 1}, q = 3$$

គេបាន $S_{15} = \frac{2(3^{15} - 1)}{3 - 1} = 14348906$

ដូចនេះ: $S_{15} = 14348906$

3.កំណត់ចំនួនតួនៃស្ទីតធរណីមាត្រខាងក្រោម:

ក, $1, 2, 4, 8, \ldots, 8192$

គេមាន $u_1 = 1, u_2 = 2$ នោះ $q = \frac{u_2}{u_1} = 2$ តាមរូបមន្ត

$U_n = u_1 . q^{n-1}$ ដែល $U_n = 8192$

គេបាន $8192 = 2^{n-1} \Leftrightarrow 2^{n-1} = 2^{13}$

$\Rightarrow n - 1 = 13 \Leftrightarrow n = 14$

ខ, $20, 10, 5, \frac{5}{2}, \ldots, \frac{5}{256}$

គេមាន $u_1 = 20, u_2 = 10$ នោះ $q = \frac{u_2}{u_1} = \frac{10}{20} = \frac{1}{2}$

តាមរូបមន្ត $U_n = u_1 . q^{n-1}$ ដែល $U_n = \frac{5}{256}$ គេបាន:

$$\frac{256}{5}=20.\left(\frac{1}{2}\right)^{n-1}$$

$$\Leftrightarrow \frac{1}{1024}=\left(\frac{1}{2}\right)^{n-1} \Leftrightarrow \left(\frac{1}{2}\right)^{n-1}=\left(\frac{1}{2}\right)^{10}$$

$$\Rightarrow n-1=10 \Leftrightarrow n=11$$

4.បង្ហាញថាស្វ៊ីតខាងក្រោមជាស្វ៊ីតធរណីមាត្រ

ក,គេមាន $U_n=7\times 3^{n-1} \Rightarrow U_{n+1}=7.3^n$

$\Leftrightarrow U_{n+1}=3\times 7.3^{n-1}=3U_n$

ដូចនេះ $(U_n)$ ជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួម $q=3$ និងតួទី 1គឺ $u_1=7$

ខ,$U_{n+1}=\frac{1}{8}\times 4^n \Leftrightarrow U_n=\frac{1}{8}\times 4^{n-1}$

$$\Leftrightarrow U_n=\frac{1}{4}\times\left(\frac{1}{8}\times 4^n\right) \Leftrightarrow U_n=\frac{1}{4}U_{n+1} \Leftrightarrow U_{n+1}=4U_n$$

ដូចនេះ $(U_n)$ ជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួម

$q=4$ និងតួទី 1គឺ $u_1=\frac{1}{8}$

5.គេអោយ $(U_n)$ ជាស្វ៊ីតធរណីមាត្រ បើគេដឹងថា:

ក, $u_3=18, u_7=1458$ ។ គណនា $q$ និង $u_{10}$

តាមរូបមន្ត $U_n = u_1.q^{n-1}$ គេបាន

$$\begin{cases} u_3 = 18 \\ u_7 = 1458 \end{cases} \Leftrightarrow \begin{cases} u_1.q^2 = 18 \quad (1) \\ u_1.q^6 = 1458 \; (2) \end{cases}$$

យក $(2)$ ចែកនឹង $(1)$ គេបាន $q^4 = 81 = 3^4 \Leftrightarrow q = \pm 3$

ដោយ $(U_n)$ ជាស្វីតធរណីមាត្រកើនគេយក $q = 3$

ជំនួស $q = 3$ ក្នុង $(1)$ គេបាន $u_1 = 2$

នាំអោយ $u_{10} = u_1.q^9 = 2 \times 3^9 = 39366$

ដូចនេះ៖ $q = 3$ និង $u_{10} = 39366$

ខ, $u_3 = 20, u_6 = 1280$ ។ គណនា $q$ និង $u_1$ ។

តាមរូបមន្ត $U_n = u_1.q^{n-1}$ $, n \geq 1$ គេបាន:

$$\begin{cases} u_3 = 20 \\ u_6 = 1280 \end{cases} \Leftrightarrow \begin{cases} u_1.q^2 = 20 \;\; (1) \\ u_1.q^5 = 1280 \; (2) \end{cases}$$

យក $(2)$ ចែកនឹង $(1)$ គេបាន:

$$q^3 = 64 \Leftrightarrow q^3 = 4^3 \Rightarrow q = 4$$

ជំនួស $q = 4$ ក្នុង $(1)$ គេបាន $u_1 = \frac{5}{4}$ ដូចនេះ៖ $q = 4$ និង

$u_1 = \frac{5}{4}$

គ, $u_1=3, s_3=21$ ។ គណនា $q$ និង $s_7$

តាមរូបមន្ត $u_n=u_1.q^{n-1}$ និង $S_n=\dfrac{u_1\left(q^n-1\right)}{q-1}$

$$\Leftrightarrow s_3=21\Leftrightarrow\frac{u_1\left(q^3-1\right)}{q-1}=21;u_1=3\Leftrightarrow\frac{3(q-1)\left(q^2+q+1\right)}{q-1}=21$$

$$\Leftrightarrow q^2+q+1=7\Leftrightarrow q^2+q-6=0$$

$$\Delta=1+24=25=5^2>0\Rightarrow q_1=\frac{-1+5}{2}=\frac{4}{2}=2$$

$$\Rightarrow q_2=\frac{-1-5}{2}=-3<0$$ ( មិនយក )

ចំពោះ $q=2$ គេបាន: $s_7=\dfrac{3\left(2^7-1\right)}{2-1}=3\times127=381$

ដូចនេះ $s_7=381$ និង $q=2$

6.គណនាផលបូកស្វ៊ីតធរណីមាត្រខាងក្រោមៈ

គេមាន $u_1=48, u_2=24$ នោះ $q=\dfrac{u_2}{u_1}=\dfrac{24}{48}=\dfrac{1}{2}$

ដោយស្វ៊ីតមាន 8 តួគេបាន

$$s_8=\frac{u_1.\left(1-q^8\right)}{1-q}=\frac{48\left(1-\frac{1}{2^8}\right)}{1-\frac{1}{2}}=\frac{48\left(2^8-1\right)}{2^7}=\frac{12240}{128}=\frac{765}{8}$$

ដូចនេះ $48+24+12+...+\frac{3}{8}=\frac{765}{8}$

ខ, $\frac{1}{3}+1+3+...+6561$

+កណាត់ចំនួនតួនៃស្វីតនេះ

តាមរូបមន្ត $U_n=u_1.q^{n-1}$ ដែល $u_1=\frac{1}{3}, q=3, U_n=6561$

គេបាន: $6561=\frac{1}{3}\times 3^{n-1} \Leftrightarrow 3^{n-2}=6561$

$\Leftrightarrow 3^{n-2}=3^8 \Rightarrow n-2=8$

$\Leftrightarrow n=10 \Rightarrow s_{10}=\frac{u_1(q-1)}{q-1}=\frac{1}{3}\times\frac{3^{10}-1}{2}=\frac{29524}{3}$

ដូចនេះ $\frac{1}{3}+1+3+...+6561=\frac{29524}{3}$

គ, $9-6+4-...-\frac{128}{243}$

+កំណត់ចំនួននៃស្វីតនេះ

គេមាន $U_n=u_1.q^{n-1}$ ដែល $u_1=9, q=-\frac{2}{3}$ និង

$U_n=-\frac{128}{243}$

គេបាន: $-\frac{128}{2187}=9\left(-\frac{2}{3}\right)^{n-1} \Leftrightarrow -\frac{128}{2187}=\left(-\frac{2}{3}\right)^{n-1}$

$$\Leftrightarrow\left(-\frac{2}{3}\right)^{7}=\left(-\frac{2}{3}\right)^{n-1} \Leftrightarrow n=8 \Rightarrow S_8=\frac{9\left[1+\left(\frac{2}{3}\right)^{8}\right]}{1+\frac{1}{3}}=\frac{3^8+2^8}{5\times3^5}=\frac{6817}{5\times3^5}=\frac{6817}{1213}$$

ដូចនេះ: $9-6+4...-\frac{128}{243}=\frac{6817}{1215}$

ឃ, $1-\frac{1}{2}+\frac{1}{3^2}-\frac{1}{2^3}+\frac{1}{3^4}-\frac{1}{2^5}-...-\frac{1}{2^{2n-1}}+\frac{1}{3^{2n}}$ .

តាង

$$S_n=\left(1+\frac{1}{3^2}+\frac{1}{3^4}+...+\frac{1}{3^{2n}}\right)-\left(\frac{1}{2}+\frac{1}{2^3}+\frac{1}{2^5}+...+\frac{1}{2^{2n-1}}\right)$$

តាង $A=1+\frac{1}{3^2}+\frac{1}{3^4}+...+\frac{1}{3^{2n}}$

ជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួម

$q=\frac{1}{9}$ និងតួទី1ស្មើ1គេបាន $A=\frac{1}{8}.\frac{9^{n+1}-1}{9^n}$

តាង $B=\frac{1}{2}+\frac{1}{2^3}+\frac{1}{2^5}+...+\frac{1}{2^{2n-1}}$

ជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួម

$q=\frac{1}{2^2}$ និងតួទី1ស្មើ $\frac{1}{2}$ គេបាន $B=\frac{2}{3}.\frac{4^n-1}{4^n}$

$$\Rightarrow S_n=\frac{1}{8}.\frac{9^{n+1}-1}{9^n}-\frac{2}{3}.\frac{4^n-1}{4^n}$$

7.គណនាផលបូកស្វ៊ីតធរណីមាត្រអនន្តតួ

គេមាន $\begin{cases}u_2=-9\\ u_5=\frac{1}{3}\end{cases}\Leftrightarrow\begin{cases}u_1.q=-9 & (1)\\ u_1.q^4=\frac{1}{3} & (2)\end{cases}$

យក $(2)$ ចែកនឹង $(1)$ គេបាន: $q^3=-\frac{1}{27}$

$$\Leftrightarrow q^3=\left(-\frac{1}{3}\right)^3\Rightarrow q=-\frac{1}{3}$$

ពី $(1)$ គេបាន $u_1=-\frac{9}{q}=27$

$$\Rightarrow S_\infty=\frac{u_1}{1-q}=\frac{27}{1+\frac{1}{3}}=\frac{81}{4}$$

8.គណនាផលធៀបរួមនៃស្វ៊ីតធរណីមាត្រអនន្តតួ

គេមាន: $\begin{cases}u_1=5\\ s_\infty=15\end{cases}$

តាមរូបមន្ត $s_{\infty}=\frac{u_1}{1-q}$ គេបាន:

$$15=\frac{5}{1-q}\Leftrightarrow 15-15q=5\Leftrightarrow 15q=10\Leftrightarrow q=\frac{10}{15}=\frac{2}{3}$$

ៗដូចនេះ $q=\frac{2}{3}$

9.គណនា $q$ និង $u_1$ $(q>0)$

គេមាន $\begin{cases} s_2=9 \\ s_{\infty}=25 \end{cases} \Leftrightarrow \begin{cases} \frac{u_1(q^2-1)}{q-1}=9 \ (1) \\ \frac{u_1}{1-q}=25 \ (2) \end{cases}$

យក $(1)$ ចែកនឹង $(2)$ គេបាន:

$$\Leftrightarrow q^2-1=-\frac{9}{25}\Leftrightarrow q^2=1-\frac{9}{25}$$

$$\Leftrightarrow q^2=\frac{16}{25}\Rightarrow q=\frac{4}{5}$$ ( ព្រោះ $q>0$ )

ដូចនេះ $q=\frac{4}{5}$

10.សរសេរចំនួនទសភាគខួបជាទំរង់ $\frac{a}{b}$

ក, $\overline{0,7}=0,7+0,07+0,007+\ldots$

$$=\frac{7}{10}+\frac{7}{100}+\frac{7}{100}+\ldots$$

តាមលំដាប់នេះវាជាស្វ៊ីតធរណីមាត្រមិនកំណត់ដែលមាន

$q=\frac{7}{10}$ និង $u_1=\frac{7}{10}$ គេបាន $s_\infty=\frac{u_1}{1-q}=\frac{\frac{7}{10}}{1-\frac{1}{10}}=\frac{7}{9}$

។ដូចនេះ $2,\overline{34}=2+\frac{34}{99}=\frac{232}{99}$

គ, $0,\overline{452}=0,452+0,000452+\ldots$

$=\frac{0,452}{1-0,001}=\frac{0,452}{0,999}=\frac{452}{999}$ ។ដូចនេះ $0,\overline{452}=\frac{452}{999}$

<u>លំហាត់ជំពូក</u>

1.តួទី 5 នៃស្វ៊ីតនព្វន្តស្មើ 14 និងតួទី 12 ស្មើ 35 ។
គណនាផលសងរួមតួទី 1 តួទី $n$ ។

2.ផលបូកនៃ $n$ តួដំបូងនៃស្វ៊ីតមួយកំណត់ដោយ $S_n=n^2+n$ ។ គណនាតួទី 5 នៃស្វ៊ីត និងបង្ហាញថាតួនៃស្វ៊ីតនេះជាស្វ៊ីតនព្វន្ត

3.តួទី 3 នៃស្វ៊ីតធរណីមាត្រស្មើ 3 និងតួទី 6 ស្មើ $\frac{3}{8}$ ។
គណនាផលធៀបរួម តួទី និងផលបូក 8 តួដំបូង ។

4.គណនា $a$ ដើម្បីឲ្យបីចំនួន $(a-3)$,$(a+1)$ និង $(4a-2)$ ជាតួតគ្នានៃស្វ៊ីតធរណីមាត្រ ។

5.គេឲ្យបួនចំនួនជាស្វ៊ីតធរណីមាត្រ ។ គណនាតួទីពីរ និងទីបីនៃស្វ៊ីតបើគេដឹងថាតួទី 1 ស្មើនឹង 6 ហើយតួទីបួនស្មើនឹង 162 ។

6.គេទិញផ្ទះមួយតម្លៃ 30000 ដុល្លា ។ អ្នកទិញត្រូវបង់ប្រាក់ជា 6 ដំណាក់កាល ដែលបង្កើតបានជាស្វ៊ីតធរណីមាត្រមានផលធៀបរួមស្មើ $\frac{9}{10}$ ។ កំណត់ប្រាក់ដែលត្រូវបង់តាមដំណាក់កាលនីមួយៗ ។

7.គេមានស្វ៊ីតនព្វន្ត $(U_n)$ និង $(V_n)$ កំណត់ដោយ $U_0 = 3$ និងផលសងរួមស្មើ 3 និង $V_0 = 3$ និងផលសងរួមស្មើ 2 ។

ក,កំណត់ $U_n$ និង $V_n$ ជាអនុគមន៍នៃ $n$ ។

ខ,គេមានស្វ៊ីត $(W_n)$ ជាស្វ៊ីតកើន ។

8.កំណត់ផលសងរួម និងតួទីមួយ $U_1$ នៃស្វ៊ីតនព្វន្ត $(U_n)_{n\in\mathbb{N}}$ កើននិងដឹងថា

$$\begin{cases} U_1^2 + U_2^2 + U_3^2 = 98 \\ U_1 - U_2 + U_3 = 4 \end{cases}$$

គណនា $U_{10}$ និងផលបូក 10 តួដំបូងនៃស្វ៊ី ។

9.តួដំបូងនៃស្ទីតធរណីមាត្រស្មើ 3 ហើយមានផលធៀបរួម $r$ ដែលតម្លៃដាច់ខាតនៃ $r$ តូចជាង 1 ។

ក.ផលបូក 3 តួដំបូង $\frac{8}{9}$ នៃផលបូក 6 តួដំបូង ។

ខ.គណនាផលបូកស្ទីតធរណីមាត្រអនន្តតួ ។

10.1,ដោះស្រាយក្នុង $\mathbb{R}$ សមីការ : $3x^2-8x+4=0 \quad (E)$ ។

2,គេមាន $(U_n)_{n\in\mathbb{N}}$ ជាស្ទីតធរណីមាត្រកើនដែលមាន $U_3$ និង $U_4$ នៃស្ទីតនេះជាចម្លើយនៃសមីការ $(E)$

ក,ទាញរកផលធៀបរួមនៃស្ទីតនេះ ។

ខ,គណនាតួទីមួយ $U_1$ នៃស្ទីត ។

## ដំណោះស្រាយ

1.គណនាផលសងរួមតួទី 1 តួទី $n$ ។

គេមាន $\begin{cases} u_5 = 14 \\ u_{12} = 35 \end{cases} \Leftrightarrow \begin{cases} u_1 + 4d = 14 \ (1) \\ u_1 + 11d = 35 \ (2) \end{cases}$

យក $(2)-(1)$ គេបាន $7d = 21 \Leftrightarrow d = 3$

$$\Rightarrow U_n = u_1 + (n-1) = 2 + (n-1).3 = 3n-1$$

| ដូចនេះ $d = 3, u_1 = 2, U_n = 3n-1$ |
|---|

2.គណនាតួទី 5 នៃស្ទីត

តាង $(a_n)$ ជាតួទី $n$ នៃស្ទីតនេះ គេបាន:

$S_n = n^2 + n \Rightarrow s_{n-1} = n^2 - n$

$$\Rightarrow s_n - s_{n-1} = 2n \Leftrightarrow a_n = 2n \Rightarrow a_5 = 10$$

+បង្ហាញថាតួនៃស្ទីតនេះជាស្ទីតនព្វន្ត

យើងមាន: $a_n = 2n \Rightarrow a_{n+1} = 2n + 2$

យើងបាន $a_{n+1} - a_n = 2n + 2 - 2n = 2$ ថេរ ដូចនេះ $(a_n)$ ជាស្ទីតនព្វន្ត

3.គណនាផលធៀបរួម និងតួទី 1

គេមាន $\begin{cases} u_3 = 3 \\ u_6 = \dfrac{3}{8} \end{cases} \Leftrightarrow \begin{cases} u_1.q^2 = 3 \ (1) \\ u_1.q^5 = \dfrac{3}{8} \ (2) \end{cases}$

យក $(2)$ ចែកនឹង $(1)$ គេបាន:

$q^3 = \dfrac{3}{24} = \dfrac{1}{8} = \left(\dfrac{1}{2}\right)^3 \Rightarrow q = \dfrac{1}{2}$ ជំនួស $(1)$ គេបាន

$u_1 = \dfrac{3}{q^2} = 3 \times 4 = 12$

**ដូចនេះ: $q = \dfrac{1}{2}, u_1 = 12$**

+គណនាផលបូក 8 តួដំបូង

តាមរូបមន្ត $S_n=\dfrac{u_1\left(1-q^n\right)}{1-q}$

$$\Rightarrow s_8=\frac{12\left[1-\left(\frac{1}{2}\right)^8\right]}{1-\frac{1}{2}}=\frac{12\left(2^8-1\right)}{2^7}$$

ដូចនេះ $s_8=\dfrac{765}{32}$

4.គណនា $a$

គេមាន: $(a-3),(a+1),(4a-2)$

ដើម្បីអោយនបីចំនួននេះជាតួតគ្នានៃស្វ៊ីតធរណីមាត្រលុះត្រាតែ

$$(a-3)(4a-2)=(a+1)^2$$

$$\Leftrightarrow 4a^2-14a+6=a^2+2a+1\Leftrightarrow 3a^2-16a+5=0$$

$$\Delta'=64-15=49=7^2>0\Rightarrow a_1=\frac{8+7}{3}=\frac{15}{3}=5,a_2=\frac{8+7}{3}=\frac{1}{3}$$

ដូចនេះ $a=5$ រឺ $a=\dfrac{1}{3}$

6.គណនាតួទី 2 និងតួទី 3 នៃស្វ៊ីតធរណីមាត្រ

តាង $u_1,u_2,u_3,u_4$ ជាបួនតួនៃស្វ៊ីតធរណីមាត្រ

ដែល $u_1 = 6$ និង $u_4 = 162$ គេបាន

$$u_2 \times u_3 = u_1 \times u_4 = 6 \times 162$$

$$\Leftrightarrow (u_1.q)(u_1.q^2) = 972 \Leftrightarrow 36q^3 = 972 \Leftrightarrow q^3 = 27 = 3^3$$

$$\Rightarrow u_2 = u_1.q = 6 \times 3 = 18, u_3 = u_2.q = 18 \times 3 = 54$$

ដូចនេះ: $u_2 = 18, u_3 = 54$

7.កំណត់ប្រាក់ដែលត្រូវបង់តាមដំណាក់កាលនីមួយៗ

តាង $u_1, u_2, u_3, u_4, u_5, u_6$

ជាទឹកប្រាក់ដែលត្រូវបង់រៀងគ្នាតាមដំណាក់កាលនីមួយៗ

គេបាន

$$u_1 + u_2 + u_3 + u_4 + u_5 + u_6 = 30000$$

$$u_1 + u_1q + u_1q^2 + u_1q^3 + u_1q^4 + u_1q^5 = 30000$$

$$u_1(1 + q + q^2 + q^3 + q^4 + q^5) = 30000$$

$$u_1(1 + q + q^2 + q^3 + q^4 + q^5) = 3000$$

$$u_1.\frac{1-q^6}{1-q} = 30000, q = \frac{9}{10}$$

$$u_1.\frac{1-\left(\frac{9}{10}\right)^6}{1-\frac{9}{10}} = 30000$$

$$u_1.4,68559 = 30000 \Leftrightarrow u_1 = \frac{30000}{4,68559} = 6402,60885$$

$$u_2 = 6402.60885 \times \frac{9}{10} = 5762.347965, u_3 = 5762.347965 \times \frac{9}{10} = 5186.113$$

$$u_4 = 5186.113 \times \frac{9}{10} = 4667.501, u_5 = 4667.501 \times \frac{9}{10} = 4200.751$$

$$u_6 = 4200.751 \times \frac{9}{10} = 3780.676$$

ដូចនេះ តម្លៃនៃ $u_1, u_2, u_3, u_4, u_5, u_6$
ខាងលើជាទឹកប្រាក់ត្រូវបង់រៀងគ្នាទាំង៦លើក ។

8.ក,កំណត់ $(U_n)$ និង $(V_n)$ ជាអនុគមន៍នៃ $n$

+គេមាន $u_0 = 3$ និង $d = 3$ គេបាន $U_n = u_0 + nd = 2$

+គេមាន $v = 0$ និង $d = 2$ គេបាន $V_n = v_0 + nd = 3 + 2n$

ខ,គេអោយ $(W_n) = \frac{U_n}{V_n}$

a)បង្ហាញថា $(W_n)$ ជាស្វ៊ីតកើន។ គេមាន

$$W_n = \frac{3n+3}{2n+3} \Rightarrow W_{n+1} = \frac{3n+6}{2n+5}$$

$$\Rightarrow W_{n+1} - W_n = \frac{3n+6}{2n+5} \frac{3n+3}{2n+3} = \frac{3}{(2n+5)(2n+3)} > 0, \forall n \in \mathbb{N}$$

ដូនេះ: $(W_n)$ ជាស្វ៊ីតកើន

២)កំណត់តម្លៃ $n$

គេមាន $W_{n+1}-W_n=W_n-W_{n-1}$

$$\Leftrightarrow \frac{3}{(2n+5)}=\frac{1}{28}\Leftrightarrow 4n^2+16n-69=0$$

$$\Delta'=64+276=340>0\Rightarrow n=\frac{-8\pm\sqrt{340}}{4}\notin\mathbb{N}$$

ដូចនេះ គ្មានតម្លៃ $n$ ណាដែលធ្វើអោយ $W_n-W_{n-1}=\dfrac{1}{28}$ ទេ ។

៩.កំណត់ផលសងរួមនិងតួទីមួយ $u_1$

គេមាន: $\begin{cases}u_1^2+u_2^2+u_3^2=98 & (1)\\ u_1-u_2+u_3=4 & (2)\end{cases}$ តែ $u_1+u_3=2u_2$

ពី $(2)$ គេបាន $u_2=4$ ជំនួសក្នុង $(1)\&(2)$ គេបាន

$$\begin{cases}u_1^2+u_3^2=82 & (3)\\ u_1+u_3=8 & (4)\end{cases}$$

ពី $(4)$: គេទាញបាន $u_3=8-u_1$ ជំនួស $(3)$

$$u_1^2+(8-u_1)^2=82\Leftrightarrow 2u_1^2-16u_1-18=0\Leftrightarrow u_1^2-8u_1-9=0$$

$$\Delta'=16+9=25=5^2>0$$

$\Rightarrow u_1' = 4+5 = 9 > u_2 = 4$ ( មិនយក ).

$u_2'' = 4-5 = -1 < u_2$ យក

ពី $(4) \Rightarrow u_3 = 8 - u_1 = 8+1 = 9$

$d = u_2 - u_1 = 4+1 = 5$ ដូចនេះ: $\boxed{d = 5, u_1 = -1}$

+គណនា $u_{10}$ និងផលបូក10តួដំបូងនៃស្វីតនេះ:

គេបាន $u_{10} = u_1 + (10-1)d = -1 + 9\times 5 = 44$

ហើយ $s_\infty = \dfrac{10}{2}(u_1 + u_{10}) = 5(-1+44) = 215$

$\boxed{\text{ដូចនេះ: } u_{10} = 44, s_\infty = 215}$

គណនាផលបូកស្វីតធរណីមាត្រអនន្តតួ

គេមាន $\begin{cases} u_1 = 3 \\ s_3 = \dfrac{8}{9}s_6 \quad (1) \end{cases}$

ពី $(1) \Leftrightarrow u_1 . \dfrac{1-r^3}{1-r} = u_1 . \dfrac{8}{9} \times \dfrac{1-r^6}{1-r}$

$\Leftrightarrow 1 - r^3 = \dfrac{8}{9}(1-r^6)$

$\Leftrightarrow \dfrac{8}{9}(1-r^3)(1+r^3) = 1 - r^3 \Leftrightarrow \dfrac{8}{9}(1+r^3) = 1$

$$\Leftrightarrow 8r^3+8=9 \Leftrightarrow r^3=\left(\frac{1}{2}\right)^3 \Leftrightarrow r=\frac{1}{2}$$

គេបាន $S_\infty=\frac{u_1}{1-r}=\frac{3}{1-\frac{1}{2}}=\frac{3}{1-\frac{1}{2}}=6$

ដូចនេះ: $S_\infty=6$

10.1.ដោះស្រាយសមីការក្នុង $\mathbb{R}$

គេមាន: $3x^2-8x+4=0 \ (E)$:

$\Delta'=16-12=4=2^2>0$

$$\Rightarrow x_1=\frac{4+2}{3}=2 \,\&\, x_2=\frac{4-2}{3}=\frac{2}{3}$$

ដូចនេះ: $x_1=2, x_2=\frac{2}{3}$

2.ក/ ទាញរកផលធៀបរួម $q$

ដោយ $u_3;u_4$ ជាចំលើយនៃសមីការ $(E)$ គេបាន

$u_3=\frac{2}{3}, u_4=2$ (ព្រោះ $(U_n)$ កើន)

$\Rightarrow q=\frac{u_4}{u_3}=\frac{2}{\frac{2}{3}}=3$ ដូចនេះ: $q=3$

ខ/គណនាតួទីមួយ $u_1$ នៃស្វ៊ីត

គេមាន $u_4 = u_1.q^3 \Leftrightarrow 2 = u_1.3^3 \Leftrightarrow u = \frac{2}{27}$

ដូចនេះ: $u_1 = \frac{2}{27}$

## ជំពូកទី 2 អនុគមន៍អិចស្ប៉ូណង់ស្យែលនិងអនុគមន៍លោការីត

### មេរៀនទី 1 អនុគមន៍អិចស្ប៉ូណង់ស្យែល

លំហាត់

1.គណនាតម្លៃកន្សោម:

ក. $\sqrt{16}$ ខ. $\sqrt{225}$ គ. $\sqrt{144}$

ឃ. $\sqrt[3]{0.008(y-2)^3}$ ង. $\sqrt{(-16x)^2}$

ច. $\sqrt[3]{27}$ ឆ. $-\sqrt[3]{64}$ ជ. $\sqrt[3]{-64x^3}$

2.សរសេរកន្សោមខាងក្រោមជាទម្រង់អិចស្ប៉ូណង់ស្យែលក. $x = \sqrt[4]{10}$ ខ. $\sqrt[5]{56} = z$

គ. $a = \sqrt[28]{500h}$ ឃ. $b = \sqrt[x]{y}$

3. សម្រួលកន្សោម

ក. $\sqrt[4]{625}$ ខ. $\sqrt[5]{-1}$ គ. $-\sqrt[5]{-32}$

ឃ. $\sqrt[5]{-\frac{1}{32}}$ ង. $\sqrt[6]{x^6}$ ច. $\sqrt[4]{(7b)^4}$

ឆ. $\sqrt[7]{y^7}$ ជ. $\sqrt[5]{(x-2)^5}$

4. រកដែនកំណត់នៃអនុគមន៍

ក. $f(x)=\sqrt{x}$ ខ. $f(x)=\sqrt[3]{x}$

គ. $f(x)=\sqrt{2x-8}$ ឃ. $f(x)=\sqrt{4-3x}$

ង. $f(x)=\sqrt{-3x^2}$ ច. $f(x)=\sqrt{x^2+1}$

ឆ. $f(x)=\dfrac{\sqrt{x}}{2x^2-3x-5}$

ជ. $f(x)=\dfrac{\sqrt{x+3}}{x^2-x-2}$ ឈ. $f(x)=\dfrac{\sqrt{x+1}}{x+|x|}$

5. គណនាកន្សោមខាងក្រោម:

ក. $\sqrt{2}.\sqrt{3}$ ខ. $\sqrt[3]{3}.\sqrt[3]{5}$ គ. $\sqrt[4]{8}.\sqrt[4]{9}.\sqrt[4]{72}$

ឃ. $\sqrt{3a}.\sqrt{10b}$ ង. $\sqrt{x-a}.\sqrt{x+a}$ ច. $\sqrt{\dfrac{6}{x}}.\sqrt{\dfrac{y}{5}}$

6. សម្រួលកន្សោម ក. $\dfrac{2}{3}\sqrt{4.5}+\dfrac{3}{2}\sqrt[3]{16}+\dfrac{1}{4}\sqrt{72}$

ខ. $x^3\sqrt{2y}-\sqrt[3]{16x^3y}+\dfrac{x}{3}\sqrt[3]{54y}$

7. ប្រៀបធៀប

ក. $5\sqrt[3]{2}$ និង $2\sqrt[3]{31}$ ខ. $\sqrt[3]{2}$ និង $\sqrt[12]{45}$ គ. $\sqrt[6]{5}$ និង $\sqrt[8]{8}$

៣. សម្រួលកន្សោម៖

ក. $\dfrac{\sqrt[3]{c^3+3c^2d+3cd^2+d^3}}{\sqrt{c^2-d^2}.\sqrt{c^2-d^2}}$ ខ. $\dfrac{\sqrt{x}}{\sqrt{x}-\sqrt{x+1}}$

$$\frac{\sqrt{p}}{\sqrt{3q^2+4pq+p^2}}.\frac{\sqrt{p+3q}}{\sqrt{p^2+6pq+8p^2}}+\frac{1}{\sqrt{q^2+3pq+2q^2}}$$

៩.សរសេរកន្សោមខាងក្រោមជាទម្រង់រ៉ាឌីកាល់

ក. $8^{\frac{1}{3}}$ ខ. $x^{\frac{1}{x}}$ គ. $y^{\frac{1}{5}}$ ឃ. $\left(a^5t^3\right)^{\frac{1}{2}}$

ង. $\left(x^3y^3\right)^{\frac{1}{4}}$ ច. $\left(x^3y^5\right)^{\frac{1}{4}}$

10. ដោះស្រាយសមីការ

ក. $2^x=32$ ខ. $(x+1)^{x^2-4x+3}=1$

គ. $\left(2-\sqrt{3}\right)^x+\left(2+\sqrt{3}\right)^x=2$ ឃ. $3^{\left(2^x\right)}=6561$

ង. $81^{\left(4^x\right)}=9$ ច. $3\left(4^x\right)+2\left(9^x\right)-5\left(6^x\right)=0$

ឆ. $3^{\left(3^x\right)}=1$ ជ. $\left(\sqrt{2+\sqrt{3}}\right)^x+\left(\sqrt{2-\sqrt{3}}\right)^x=4$

11. ដោះស្រាយសមីការ

ក. $2^x>1$ ខ. $3^x\le 1$ គ. $2^{2x}\le\dfrac{1}{16}$

ឃ. $16^x < 8^{x+1}$  ង. $32^{5x+2} \geq 16^{5x}$  ច. $4^{3x-1} > \frac{1}{256}$

12. ដោះស្រាយសមីការ

ក. $16^x > 0.125$  ខ. $2^x > -8$  គ. $(02.)^x \leq 25$

ង. $3^x \leq \sqrt[3]{9}$  ច. $\left(\frac{1}{2}\right)^x > \sqrt[3]{\frac{1}{4}}$

13. មីងសយបានយកប្រាក់មួយចំនួនទៅផ្ញើនៅធនាគារមួយ ដោយទទួលបានអត្រាការប្រាក់ 6% ក្នុងមួយឆ្នាំ ។ រយៈពេល 7 ឆ្នាំក្រោយមក គាត់បានដកប្រាក់ពីធនាគារនោះវិញ ដោយទទួលបានប្រាក់សរុបចំនួន 300 ដុល្លារ។ តើមីងសយមានប្រាក់ដើមចំនួនប៉ុន្មាន ?

14. មនុស្សម្នាក់មានអាយុ 30 ឆ្នាំ បានយកប្រាក់ 5 000 រៀល ទៅផ្ញើនៅធនាគារមួយ ដោយទទួលបានអត្រាការប្រាក់ 4%ក្នុងមួយឆ្នាំ ។ តើគាត់មានប្រាក់សរុបចំនួនឱប៉ុន្មានបើបច្ចុប្បគាត់មានអាយុ 65 ឆ្នាំ ។

15. មនុស្សបានទិញរថយន្តថ្មីមួយគ្រឿងក្នុងតម្លៃ 45 000 ដុល្លារ ។រថយន្តចុះថ្លៃ 15%ជារៀលរាល់ឆ្នាំ ។

រកតម្លៃរថយន្តក្នុងរយៈពេល 7 ឆ្នាំក្រោយ ។

## <u>ដំណោះស្រាយ</u>

1.គណនាតំលៃកន្សោមៈ

ក. $\sqrt{16}=4$ ខ, $\sqrt{225}=\sqrt{(15)^2}=15$

គ. $\sqrt{144}=\sqrt{(12)^2}=12$

ឃ. $\sqrt[3]{0,008(y-2)^3}=\sqrt[3]{\left[0,2(y-2)^3\right]}=0,2(y-2)$

ង. $\sqrt{(-6x)^2}=|6x|$ ច. $\sqrt[3]{27}=\sqrt[3]{3^3}=3$

ឆ. $-\sqrt[3]{64}=-\sqrt[3]{4^3}=-4$

ជ. $\sqrt[3]{64x^3}=\sqrt[3]{(-4x^3)}=-4x$

2.សរសេរកន្សោមខាងក្រោមជាទម្រង់អ៊ិចស្ប៉ូ

ក. $x=\sqrt[4]{10}=10^{\frac{1}{4}}$ ខ. $\sqrt[8]{56}=k\Leftrightarrow k=(56)^{\frac{1}{8}}$

គ. $a=\sqrt[28]{500h}=(500h)^{\frac{1}{28}}$ ឃ. $b=\sqrt[x]{y}=y^{\frac{1}{x}}$

3.សំរួលកន្សោម

ក. $\sqrt[4]{625}=\sqrt[4]{5^4}=5$ ខ. $\sqrt[5]{-1}=\sqrt[5]{(-1)^5}=-1$

គ. $-\sqrt[5]{-32}=-\sqrt[5]{(-2)^5}=2$

ឃ. $\sqrt[5]{-\frac{1}{32}}=-\sqrt[5]{\left(-\frac{1}{2}\right)^5}=-\frac{1}{2}$ ង. $\sqrt[6]{x^6}=|x|$

ច. $\sqrt[4]{(7b)^4}=7|b|$ ឆ. $\sqrt[7]{y^7}=y$ ជ. $\sqrt[5]{(x-2)^5}=x-2$

4.រកដែនកំណត់នៃអនុគមន៍

ក. $f(x)=\sqrt{x}$ , $D=[0,+\infty)$

ខ. $f(x)=\sqrt[3]{x}$ , $D=(-\infty;+\infty)$

គ. $f(x)=\sqrt{2x+8}$

អនុគមន៍ $f$ មានន័យកាលណា $4-3x\geq 0$ រឺ $x\geq -\dfrac{8}{2}$

$$\Rightarrow D=\left[-\frac{8}{2};+\infty\right)$$

ង. $f(x)=\sqrt{-3x^2}$

អនុគមន៍ $f$ មានន័យកាលណា $-3x^2\geq 0$ តែ $x^2\geq 0$

$$\Rightarrow -3x^2\leq 0\Rightarrow -3x^2=0\Leftrightarrow x=0$$
$$\Rightarrow D=\{0\}$$

ច. $f(x)=\sqrt{x^2+1}$ មានន័យកាលណា $\forall x\in\mathbb{R}$

$$\Rightarrow D=\mathbb{R}=(-\infty;+\infty)$$

ឆ. $f(x)=\dfrac{\sqrt{x}}{2x^2-3x-5}$

អនុគមន៍ $f$ មានន័យកាលណា $\begin{cases} x \geq 0 \\ 2x^2 - 3x - 5 \neq 0 \ (1) \end{cases}$

(1) សរសេរជាសមីការ $2x^2 - 3x - 5 = 0$

$x_1 = -1, x_2 = \frac{5}{2}$ (ព្រោះ $b = a + c$ )

ដូចនេះ $D = [0, +\infty) \setminus \left\{\frac{5}{2}\right\}$

ជ. $f(x) = \frac{\sqrt{x+3}}{x^2 - x - 2}$

អនុគមន៍ $f$ មានន័យកាលណា $\begin{cases} x + 3 \geq 0 \ (1) \\ x^2 - x - 2 \neq 0 \ (2) \end{cases}$

ពី $(1): x + 3 \geq 0 \Leftrightarrow x \geq -3$

+សរសេរ $(2): x^2 - x - 2 = 0$ មានរឹស $x_1 = -1, x_2 = 2$

ដូចនេះ: $D = [-3, +\infty) - \{-1, 2\}$

ឈ. $f(x) = \frac{\sqrt{x+1}}{x + |x|}$

អនុគមន៍ $f$ មានន័យកាលណា $\begin{cases} x + 1 \geq 0 \\ x + |x| \neq 0 \end{cases}$

$$\Leftrightarrow \begin{cases} x \geq -1 \\ x > 0 \end{cases}$$

ដូចនេះ: $D = (0, +\infty)$

5.គណនាកន្សោមខាងក្រោម:

ក. $\sqrt{2}.\sqrt{3} = \sqrt{2\times 3} = \sqrt{6}$  ខ. $\sqrt[3]{3}.\sqrt[3]{5} = \sqrt[3]{3\times 5} = \sqrt[3]{15}$

គ. $\sqrt[4]{8}.\sqrt[4]{9}.\sqrt[4]{72} = \sqrt[4]{8\times 9\times 72} = \sqrt[4]{(72)^2} = \sqrt{72}$

ឃ. $\sqrt{3a}.\sqrt{10b} = \sqrt{3a\times 10b} = \sqrt{30ab}$

ង. $\sqrt{x-a}.\sqrt{x+a} = \sqrt{(x-a)(a+a)} = \sqrt{(x-a)^2} = |x-a|$

ច. $\sqrt{\frac{6}{x}}.\sqrt{\frac{y}{5}} = \sqrt{\frac{6}{x}\times\frac{y}{5}} = \sqrt{\frac{6y}{5x}}$

6.សំរួលកន្សោម:

ក. $\frac{2}{3}\sqrt{4,5} + \frac{3}{2}\sqrt[3]{16} + \frac{1}{4}\sqrt{72}$

$= \frac{2}{3}\sqrt{\frac{3^2}{2}} + \frac{3}{2}\sqrt[3]{2^3\times 2} + \frac{1}{4}.\sqrt{6^2\times 2} = \frac{2\sqrt{2}}{2} + 3\sqrt[3]{2} + \frac{3\sqrt{2}}{2}$

$= \frac{5\sqrt{2}}{2} + 3\sqrt[3]{2}$

ខ. $x\sqrt[3]{2y} - \sqrt[3]{16x^3y} + \frac{x}{3}\sqrt[3]{54y}$

$= x\sqrt[3]{2y} - \sqrt[3]{(2x)^3 2y} + \frac{x}{3}\sqrt[3]{3^3.2y}$

$= x\sqrt[3]{2y} - 2x\sqrt[3]{2y} + x\sqrt[3]{2y} = 0$

7.ប្រៀបធៀប

ក. $5\sqrt[3]{2}$ និង $2\sqrt[3]{31}$

តាង $A = 5\sqrt[3]{2} \Rightarrow A^3 = 125\times 2 = 250$

តាង $B = 2\sqrt[3]{31} \Rightarrow B^3 = 8\times 31 = 248$

គេបាន $A^3 > B^3 \Leftrightarrow A > B \Leftrightarrow 5\sqrt[3]{2} > 2\sqrt[3]{31}$

ខ. $\sqrt[3]{2}$ និង $\sqrt[12]{45}$

តាង $A = \sqrt[3]{2} \Rightarrow A^{12} = 2^4 = 16$

តាង $B = \sqrt[12]{45} \Rightarrow B^{12} = 45$

គេបាន $A^{12} < B^{12} \Leftrightarrow A < B \Leftrightarrow \sqrt[3]{2} < \sqrt[12]{45}$

គ. $\sqrt[6]{5}$ និង $\sqrt[8]{8}$

តាង $A = \sqrt[6]{5} \Rightarrow A^{24} = 5^4 = 625$

តាង $B = \sqrt[8]{8} \Rightarrow B^{24} = 8^3 = 512$

គេបាន $A^{24} > B^{24} \Leftrightarrow A > B \Leftrightarrow \sqrt[6]{5} > \sqrt[8]{8}$

8.សំរួលកន្សោម

ខ. $\dfrac{\sqrt{x}}{\sqrt{x}-\sqrt{x+1}}=\dfrac{\sqrt{x}\left(\sqrt{x}+\sqrt{x+1}\right)}{\left(\sqrt{x}-\sqrt{x+1}\right)\left(\sqrt{x}+\sqrt{x+1}\right)}$

$$\frac{\sqrt{x}\left(\sqrt{x}+\sqrt{x+1}\right)}{x-x-1}=-\sqrt{x}\left(\sqrt{x}+\sqrt{x+1}\right)$$

គ. $\dfrac{\sqrt{p}}{\sqrt{3q^2+4pq+p^2}}\cdot\dfrac{\sqrt{p+3q}}{\sqrt{p^2+6pq+8q^2}}\div\dfrac{1}{\sqrt{q^2+3pq+2q^2}}$

$$=\frac{\sqrt{p(p+3q).(3q^2+3pq)}}{\sqrt{3q^2+4pq+p^2}.\sqrt{p^2+6pq+8q^2}}$$

$$=\frac{\sqrt{9pq^3+12p^2q^2+3p^3q+p^2}}{\sqrt{3q^2+4pq+p^2}.\sqrt{p^2+6pq+8q^2}}$$

$$=\frac{\sqrt{3qp}}{\sqrt{p^2+6pq+q^2}}$$

៩.សរសេរកន្សោមខាងក្រោមជាទម្រង់រ៉ាឌីកាល់

ក. $8^{\frac{1}{3}}=\sqrt[3]{8}$ ខ. $x^{\frac{1}{4}}=\sqrt[4]{x}$ គ. $y^{\frac{1}{5}}=\sqrt[5]{y}$

ឃ. $\left(x^3t^3\right)^{\frac{1}{2}}=\sqrt{a^5t^3}$ ង. $\left(x^3y^3\right)^{\frac{1}{4}}=\sqrt[4]{x^3y^3}$

ច. $\left(x^3y^5\right)^{\frac{1}{4}}=\sqrt[4]{x^3y^5}$

10.ដោះស្រាយសមីការ

ក. $2^x = 31 \Leftrightarrow 2^x = 2^5 \Rightarrow x = 5$ ខ. $(x+1)^{x^2-4x+3} = 1$

$\Leftrightarrow (x+1)^{x^2-4x+3} = (x+1)^0 \Leftrightarrow x^2 - 4x + 3 = 0$

$\Rightarrow x_1 = 1, x_2 = 3$

ង. $81^{(4^x)} = 9 \Leftrightarrow 9^{2.(4^x)} = 9$

$\Leftrightarrow 2.4^x = 1 \Leftrightarrow 2^{2x} = \frac{1}{2} = 2^{-1} \Rightarrow 2x = -1 \Leftrightarrow x = -\frac{1}{2}$

ច. $3.(4^x) + 2(9^x) - 5(6^x) = 0$ ចែកនឹង $(4^x)$

$\Leftrightarrow 3 + 2\left(\frac{9}{4}\right)^x - 5\left(\frac{6}{4}\right)^x = 0 \Leftrightarrow 3 + 2\left(\frac{9}{4}\right)^x - 5\left(\frac{3}{2}\right)^x + 3 = 0$

តាង $u = \left(\frac{2}{3}\right)^x, u > 0$ គេបាន:

$2u^2 - 5u + 3 = 0 \Rightarrow u_1 = 1, u_2 = 3$

យើងបាន: $V(t) = \frac{ds}{dt} = \frac{d}{dt}(9.8t^2) = 19.6t$

ចំពោះ $t = 2s$ យើងបាន: $V(2) - 39.2m/s$

ដោយល្បឿន $V$ មានទិសដៅចុះក្រោម នោះ

យើងបាន: $V = -39.2m/s$

គ. រកល្បឿនធ្លាក់នៃដុំថ្មនៅពេលធ្លាក់ប៉ះផ្ទៃដី

យើងមាន: $V(t) = 19.6t$ ដុំថ្មធ្លាក់ប៉ះផ្ទៃដីនៅខណៈពេល

$t=3s$ យើងបាន: $V(3)=19.6\times 3=58.8m/s$

តែ $V$ មានទិសដៅចុះក្រោម យើងបាន: $\boxed{V=-58.8m/s}$

11. ក. រកល្បឿននៃវត្ថុនៅខណៈ $t$ បន្ទាប់ពីបាញ់

យើងមាន: $S(t)=-4.9t^2+39.2t$

យើងបាន: $V(t)=\frac{ds}{dt}=\frac{d}{dt}(-4.9t^2+39.2t)$

$V(t)=-9.8t+39.2m/s$

ខ. រករយៈពេលដែលវត្ថុស្ថិតនៅកំពស់ខ្ពស់បំផុត

វត្ថុស្ថិតនៅខ្ពស់បំផុតលុះត្រាតែ $V(t)=0$

យើងបាន: $-9.8t+39.2=0$ នាំអោយ $t=\frac{39.2}{9.8}=4s$

ដូចនេះ $\boxed{t=4s}$

+ រកកំពស់នោះ ចំពោះ $t=4s$ យើងបាន:

$S(4)=-4.9\times 4^2+39.2\times 4=78.4m$

ដូចនេះ $s=78.4m$

គ. រករយៈពេលដែលវត្ថុស្ថិតក្នុងលំហអាកាស

វត្ថុស្ថិតក្នុងលំហអាកាសលុះត្រាតែចំងាយចរ

$S(t)=0\Leftrightarrow -4.9t^2+39.2t=0$

នាំអោយ $t=0$ (មិនយក) ឬ $t=\frac{39.2}{4.9}=8s$

ដូចនេះ វត្ថុស្ថិតក្នុងលំហអាកាសរយៈពេល $t = 8s$

ឃ. រកចំងាយចរសរុបនៃវត្ថុ គឺជាចំងាយចរទាំងទៅទាំងមក

យើងបាន: $s_{សរុប} = 2\times78.4m = 156.8m$

ដូចនេះ: $\boxed{s_{សរុប} = 156.8m}$

<u>មេរៀនទី៣</u>

## អថេរភាពនិងក្រាបនៃអនុគមន៍

### <u>លំហាត់</u>

- អនុគមន៍ $y = ax^3 + bx^2 + c + d \quad (a \neq 0)$

1. សិក្សាអថេរភាពនិងសង់ក្រាបតាងអនុគមន៍ខាងក្រោម:

ក. $y = x^3 + 4x$ ខ. $y = -2x^3 - 6x - 8$

គ. $y = x^3 - 6x^2 + 9x - 4$

ឃ. $y = \frac{1}{3}x^3 - x^2 + x - \frac{1}{3}$

ង. $y = \frac{1}{3}x^3 - 2x^2 + 3x + 1$

2. អនុគមន៍ $f$ កំណត់ដោយ $f(x) = x^3 - 3x + 2$ ហើយមានក្រាប $C$ ។

ក.បង្ហាញថាចំណុច $I(0,2)$ ជាចំណុចរបត់និងជាផ្ចិតឆ្លុះនៃ $C$ ។

ខ. រកសមីការបន្ទាត់ប៉ះនឹងក្រាប $C$ ត្រង់ចំណុចរបត់ $I$ ។

គ. សង់តារាងអថេរភាពនៃ $f$ និងក្រាប $C$ ក្នុងតម្រុយអរតូណរម៉ាល់។

3. អនុគមន៍ $y=x^3+mx+5$ កំណត់លើ $\mathbb{R}$ ហើយ $m$ ជាប៉ារ៉ាម៉ែត។

ក.តម្លៃដើម្បីអោយអនុគមន៍មានអតិបរមាធៀប និង អប្បបរមាធៀប ។

ខ.សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ចំពោះ $m=-3$

4. អនុគមន៍ $f$ កំណត់នៅលើ $\mathbb{R}$ ដោយ

$f(x)=ax^3+bx^2+cx+d$

ក. រកតម្លៃនៃលេខមេគុណ $a, b, c$ និង $d$ ដោយដឹងថាអនុគមន៍មានអតិបរមាធៀប $y=4$ ត្រង់ $x=1$ ហើយក្រាបប៉ះនឹងអ័ក្សអាប់ស៊ីសត្រង់ $x=3$ ។

ខ. សិក្សាអថេរភាព និង សង់ក្រាបតាង

$f(x)=x^3-6x^2+9x$ ។

5. អនុគមន៍ $f_a(x)=x^3-1-a(x-1)$ មានក្រាប $c_a$ ទៅតាមតម្លៃប៉ារ៉ាម៉ែត $a$ នីមួយៗ។

ក. រកតម្លៃ $a$ ដើម្បីអោយក្រាប $c_a$ ប៉ះនឹងអ័ក្សអាប់ស៊ីស។

ខ. សិក្សាអថេរភាពនិងសង់ក្រាបតាងអនុគមន៍ចំពោះតម្លៃ $a$ ដែលរកបាន។

6. អនុគមន៍ $y=x^3-x$ មានក្រាប $C$ ។

ក. បង្ហាញថា $A(-1,0)$ ជាចំណុចប្រសព្វមួយរវាងក្រាប $C$ និងបន្ទាត់ $L$ មានសមីការ $y=a(x+1)$ ។

ខ. រកសមីការបន្ទាត់ប៉ះនឹងក្រាប $C$ ត្រង់ចំណុច $A$ ។

គ. រកតម្លៃ $a$ ដើម្បីអោយ $L$ កាត់ក្រាប ត្រង់ពីរចំណុចផ្សេងគ្នា $M_1$ និង $M_2$ ក្រៅពីចំណុច $A$ ។ រកសំណុំ ចំណុចកណ្តាល $I$ នៃអង្កត់ $[M_1M_2]$ ។

- អនុគមន៍ $y=ax^4+bx^2+c \qquad (a\neq 0)$

7. សិក្សាអថេរភាពនិង សង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក. $y=x^4+2x^2-3$ ខ. $y=-\dfrac{1}{2}x^4-x^2+\dfrac{3}{2}$

គ. $y=x^4-4x^2$ ឃ. $y=x^4-2x^2+2$

ង. $t=2x^2-x^4$ ច. $y=x^4-6x^2+5$

8. គេអោយអនុគមន៍ $y=x^4-mx^2+3$ ដែល $m$ ជាប៉ារ៉ាម៉ែត។

ក. រកតម្លៃ $m$ ដើម្បីអោយក្រាបនៃអនុគមន៍នេះមានចំណុចរបត់ពីរ ។

ខ. រកតម្លៃ $m$ ម្បីអោយក្រាបនៃអនគមន៍គ្មានចំណុចរបត់។

9. អនុគមន៍ $y=\dfrac{1}{2}x^4-3x^2+\dfrac{3}{2}$ មានក្រាប $C$ ។

ក. សង់តាក់ងអថេរភាពនៃអនុគមន៍នេះ។ រកចំណុចរបត់នៃក្រាប $C$ ។

ខ. រកសមីការបន្ទាត់ប៉ះត្រង់ចំណុចរបត់។

គ. រកសមីការបន្ទាត់ទាំងអស់ដែលកាត់តាមចំណុច

$A\left(0, \frac{3}{2}\right)$ ហើយប៉ះនឹងក្រាប $C$ ។

10. អនុគមន៍ $f$ កំណត់ដោយ

$f(x) = -x^4 + 2mx^2 - 2m + 1$ ហើយមានក្រាប $C_m$ ។

ក. រកតម្លៃ $m$ ដើម្បីអោយអនុគមន៍ $f$ មានអតិបរមាធៀបពីរនិង អប្បបរមាធៀបមួយ។

ខ. សិក្សាអថេរភាព និង សង់ក្រាបតាងអនុគមន៍ $f$ ចំពោះ $m = 5$ ។

គ. រកតម្លៃ $m$ ដើម្បីអោយក្រាប $C_m$ កាត់អ័ក្សអាប់ស៊ីសត្រង់បួនចំណុចផ្សេងគ្នា។

- អនុគមន៍ $y = \dfrac{ax+b}{cx+d}$ $(c \neq 0,\ ad - bc \neq 0)$

11. បង្ហាញថាបន្ទាត់ដែលបានអោយ គឺជាអាស៊ីមតូតនៃក្រាបតាង $f$ :

ក. $f(x) = \dfrac{2x+1}{x}$ បន្ទាត់ $L_1 : x = 0, L_2 : y = 2$ ។

ខ. $f(x)=\dfrac{-3x+1}{x+2}$ បន្ទាត់ $L_1: x=-2, L_2: y=-3$ ។

12. សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y=\dfrac{1}{x-3}$ ខ. $y=\dfrac{x+1}{x-1}$ គ. $y=\dfrac{2x}{x+1}$

ឃ. $y=\dfrac{1-2x}{2(x-2)}$ ង. $y=\dfrac{2-3x}{1-x}$

ច. $y=\dfrac{1-x}{x-3}$ ចំពោះ $x\in(3,+\infty)$

ឆ. $y=\dfrac{x-2}{2x}$ ចំពោះ $x\in(-\infty, 2)$ ។

13. អនុគមន៍ $f(x)=\dfrac{ax+b}{cx+d}$ មានក្រាប $H$ ។

ក. រកមេគុណ $a, b, c$ និង $d$ ដោយដឹងថាក្រាប $H$ កាត់តាមចំណុច $E(-3, -1), F(0,5)$ និង $G(3,2)$ ។

ខ. រកមេគុណ $a, b, c$ និង $d$ ដោយដឹងថាបន្ទាត់ $L_1: x=2$ ជាអាស៊ីមតូតឈរនៃក្រាប $H$ ហើយបន្ទាត់ $L_2: y=\dfrac{3}{2}x+1$ ប៉ះនឹងក្រាប $H$ ត្រង់ចំណុច $A(0,1)$ ។

14. អនុគមន៍ $y=\dfrac{x+b}{cx+d}$ មានក្រាប $H$ ។

ក. រកមេគុណ $b, c, d$ ដើម្បីអោយក្រាប $H$ កាត់អ័ក្សអាប់ស៊ីសត្រង់ $x=-1$ កាត់អ័ក្សអរដោនេត្រង់ $y=-1$ និងកាត់តាម $A(2, 3)$ ។

ខ. សិក្សាអថេរភាពនិងសង់ក្រាប $H$ នៃ $f$ ។

គ. កំណត់ចំណុចប្រសព្វរវាងក្រាប $H$ និងបន្ទាត់ $L: y=x$

15. គេអោយអនុគមន៍ $y=\dfrac{2px+1}{x-p}$ ដែលមានក្រាប $H_p$ និង $p$ ជាប៉ារ៉ាម៉ែត។

ក. សិក្សាអថេរភាពនិងសង់ក្រាប $H_1$ នៃអនុគមន៍ចំពោះ $p=1$ ។

ខ. រកកូអរដោនេនៃចំណុចប៉ះ $A$ រវាងក្រាប $H_1$ និងបន្ទាត់ដែលមានមេគុណប្រាប់ទិសស្មើ $-\dfrac{1}{3}$ ។

គ. រកសមីការអាស៊ីមតូតទាំងពីរនៃក្រាប $H_p$ ។ រកសំណុំចំណុចនៃចំណុចប្រសព្វ រវាងអាស៊ីមតូតទាំងពីរ កាលណា $p$ ប្រែប្រួលតម្លៃ។

## ដំណោះស្រាយ

1. សិក្សាអថេរភាពនិងសង់ក្រាបតាងអនុគមន៍:

ក. $y=x^3+4x$

+ ដែលកំណត់ $D=\mathbb{R}$

+ ទិសដៅអថេរភាព $y'=3x^2+4$

$y'=0$ គ្មានរឹសនោះអនុគមន៍គ្មានបរមាធៀបទេ។

+ លីមីត: $\lim\limits_{x\to\pm\infty} y=\lim\limits_{x\to\pm\infty}(x^3+4x)=\pm\infty$

+ តារាងអថេរភាព

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $y'$ | | $+$ | |
| $y$ | $-\infty$ | $\nearrow$ | $+\infty$ |

+ ចំណុចរបត់ $y''=6x$ បើ $y''=0 \Rightarrow x=0, y(0)=0$

ដូចនេះ ចំនុច $(0,0)$ ជាចំណុចរបត់នៃក្រាប $C$

+ ក្រាប

- ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស: $x=0, y=0$
- បន្ទាត់ប៉ះនឹងក្រាបត្រង់ចំណុចរបត់ $I(0,0)$ មានមេគុណប្រាប់ទិស $y'(0)=4$ មានសមីការ:

$y=4(x-0)+0=4x$



ខ. $y=-2^3-6x-8$

+ ដែនកំណត់ $D=\mathbb{R}$

+ ទិសដៅអថេរភាព: $y'=-6x^2-6$

$y'=0$ គ្មានរឹសនោះអនុគមន៍គ្មានបរមាធៀបទេ។

+ លីមីត: $\lim\limits_{x\to-\infty} y=\lim\limits_{x\to-\infty}(-2x^3-6x-8)=+\infty$

$$\lim_{x\to+\infty} y=\lim_{x\to+\infty}(-2x^3-6x-8)=-\infty$$

+ តារាងអថេរភាព

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $y'$ | | $-$ | |
| $y$ | $+\infty$ | $\searrow$ | $-\infty$ |

+ ចំណុចរបត់ $y''=-12x$ បើ

$y''=0\Rightarrow x=0, y=y(0)=-8$

+ ក្រាប:

• ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស: $x=0, y=-8$

បើ $y=0$ គេបាន $-2x^3-6x-8=0$

$\Leftrightarrow (x+1)\left[-2\left(x^2-x+4\right)\right]=0 \Leftrightarrow x=-1$

ព្រោះ: $-2(x^2-x+4)=0$ គ្មានរឹស

• បន្ទាត់ប៉ះនឹងក្រាបត្រង់ចំណុចរបត់ $I(0,-8)$ មានមេគុណប្រាប់ទិស $y'(0)=-6$ និងមានសមីការ:

$y=-6(x-0)-8=-6x-8$




គ. $y=x^3-6x^2+9x-4$

+ដែនកំណត់ $D=\mathbb{R}$

+ ទិសដៅអថេរភាព:

$y'=3x^2-12x+9$

$y'=0 \Leftrightarrow 3x^2-12x+9=0$

$\Leftrightarrow (x-1)(3x-9)=0 \Leftrightarrow x=1, x=3$

• សញ្ញានៃ $y'$

| $x$ | $-\infty$ | | $1$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | $0$ | $+$ | |

• តម្លៃបរមាធៀប:

$y$ មានអប្បបរមាធៀបត្រង់ $x=3$ ហើយ $y(3)=-4$

$y$ មានអប្បបរមាធៀបត្រង់ $x=1$ ហើយ $y(2)=0$

+ លីមីត $\lim\limits_{x\to\pm\infty}(x^3-6x^2+9x-4)=\pm\infty$

+ តារាងអថេរភាព

| $x$ | $-\infty$ | | $1$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $y$ | $-\infty$ | $\nearrow$ | $0$ | $\searrow$ | $-4$ | $\nearrow$ | $+\infty$ |

+ ចំណុចរបត់: $y''=6x-12$ បើ $y''=0 \Rightarrow x=2$ ហើយ

$y(2)=-2$

+ ក្រាប:

• ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស: បើ $x=0$

គេបាន: $y=-4$ ។ បើ $y=0$ គេបាន:

$x^3-6x^2+9x-4=0 \Leftrightarrow (x-1)(x^2-5x+4)=0$

$\Leftrightarrow x=1$ រឺ $x=4$

• បន្ទាត់ប៉ះត្រង់ចំណុចរបត់ $I(2;-2)$ មានមេគុណប្រាប់ ទិស $y'(2)=-3$ ហើយមានសមីការ

$y=-3(x-2)-2=-3x+4$




ឃ. $y=\frac{1}{3}x^3-x^2+x-\frac{1}{3}$

+ដែនកំណត់ $D=\mathbb{R}$

+ ទិសដៅអថេរភាព: $y'=x^2-2x+1$ បើ

$y'=0 \Leftrightarrow x^2-2x+1=0 \Leftrightarrow x=1 \qquad (\Delta=0)$

•សញ្ញានៃ $y'$:

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | |

+ លីមីត $\lim_{x\to\pm\infty}(\frac{1}{3}x^3-x^2+x-\frac{1}{3})=\pm\infty$

+ តារាងអថេរភាព:

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $+$ | |
| $y$ | $-\infty$ | $\nearrow$ | $0$ | $\nearrow$ | $+\infty$ |

+ ចំណុចរបត់: $y''=2x-2$ បើ $y''=0\Rightarrow x=1$

ហើយ $y(1)=0$

+ ក្រាបៈ

• ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្សៈ បើ $x=0$

គេបានៈ $y=-\dfrac{1}{3}$ ហើយ បើ $y=0$ គេបានៈ

$$\frac{1}{3}x^3-x^2+x-\frac{1}{3}=0\Leftrightarrow(x-1)\left[\frac{1}{3}\left(x^2-2x+1\right)\right]=0$$

$\Leftrightarrow x=1$ ព្រោះ $x^2-2x+1$ មានរឹសឌុប $x_0=1$ ។

• បន្ទាត់ប៉ះត្រង់ចំណុចរបត់ $I(1;\,0)$ មានមេគុណប្រាប់ទិស $y'(1)=0$ ហើយមានសមីការ $y=0$

2. ក. បង្ហាញថាចំណុច $I(0,\,2)$ ជាចំណុចរបត់និងជាផ្ចិតឆ្លុះនៃក្រាប $C$

យើងមានៈ $f(x)=x^3-3x+2$

យើងបានៈ $f'(x)=3x^2-3;\ f''(x)=6x$

$f''(x)=0$ នោះ $x=0$

សញ្ញានៃ $f''(x)$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f''(x)$ | | $-$ | $0$ | $+$ | |

$f''(x)$ ប្តូរសញ្ញានៅសងខាង $x=0$ ។

ចំពោះ $x=0 \Rightarrow y=f(0)=2$ ។

ដូចនេះ $I(0,\ 2)$ ជាចំណុចរបត់នៃក្រាប $C$

+ បង្ហាញថា $I(0,\ 2)$ ជាផ្ចិតឆ្លុះនៃក្រាប $C$

យើងមាន: $f(2\times 0-x)+f(x)=f(-x)+f(x)$

$=-x^3+3x+2-x^3-3x+2=4=2\times 2$

ដូចនេះ $I(0,\ 2)$ ជាផ្ចិតឆ្លុះនៃក្រាប

ខ. រកសមីការបន្ទាត់ប៉ះនឹងក្រាប $C$ ត្រង់ចំណុច $I$

យើងមាន: $y=f'(x_0)(x-x_0)+y_0)+y_0$

ដែល $f'(x_0)=f'(0)=-3$ ហើយ $y_0=f(2)=4$

ដូចនេះ $y=-3(x-0)+4$ ឬ $y=-3x+4$

គ. សង់តារាងអថេរភាពនៃ $f$ និងក្រាប $c$

• បើ $f'(x)=0 \Leftrightarrow 3x^2-3=0 \Leftrightarrow x=\pm 1$

• $\lim\limits_{x\to\pm\infty} f(x)=\lim\limits_{x\to\pm\infty}(x^3-3x+2)=\pm\infty$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-4$ | ↘ | $0$ | ↗ | $+\infty$ |

• ចំណុចប្រសព្វរវាងក្រាបនិងអ័ក្ស: បើ $x=0,\ y=2$

បើ $y=0 \Leftrightarrow x^3-3x+2=0 \Leftrightarrow x=1,\ x=-2$




3. ក. កំណត់តម្លៃ $m$ ដើម្បីអោយអនុគមន៍មាន អតិបរមា និង អប្បបរមាធៀប

យើងមាន: $f(x)=x^3+mx+5$

$\Rightarrow f'(x)=3x^2+m$

អនុគមន៍មានអតិបរមា និង អប្បបរមាធៀបលុះត្រាតែ $f'(x)=0$ មានឫសពីរផ្សេងគ្នា យើងបាន:

$3x^2+m=0$ មានឫសពីរកាលណា $m<0$

ដូចនេះ $m<0$

ខ. សិក្សាអថេរភាពនិងសង់ក្រាបបំពោះ $m<-3$

យើងបាន: $f(x)=x^3-3x+5$ មាន $D=\mathbb{R}$

$\Rightarrow f'(x)=3x^2-3$ បើ $f'(x)=0$ នោះ $x=\pm1$

• $\lim\limits_{x\to\pm\infty} f(x)=\lim\limits_{x\to\pm\infty}\left(x^3-3x+5\right)=\pm\infty$

តារាងអថេរភាពនៃអនុគមន៍

| $x$ | $-\infty$ | | $1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $7$ | $\searrow$ | $3$ | $\nearrow$ | $+\infty$ |

•ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស: បើ $x=0, y=5$

បើ $y=0 \Leftrightarrow x^3-3x+5=0 \Leftrightarrow x\simeq -2,33$




4. ក. រកតំលៃលេខមេគុណ $a, b, c$ និង $d$

យើងមាន: $f(x)=ax^3+bx^2+cx+d$

$$f'(x)=3ax^2+2bx+c$$

ដោយ $f$ មានអតិបរមាធៀប $y=4$ ត្រង់ $x=1$ និងក្រាប ប៉ះអ័ក្សអាប់ស៊ីសត្រង់ $x=3$ យើងបាន:

$$\begin{cases} f(1)=4 \\ f'(1)=0 \\ f(3)=0 \\ f'(3)=0 \end{cases} \Leftrightarrow \begin{cases} a+b+c+d=4 & (1) \\ 3a+2b+c=0 & (2) \\ 27a+9b+3c+d=0 & (3) \\ 27a+6b+c=0 & (4) \end{cases}$$

ដោយដោះស្រាយប្រព័ន្ធសមីការនេះយើងបាន:

$$\boxed{a=1,\ b=-6,\ c=9,\ d=0}$$

ខ. សិក្សាអថេរភាពនិងសង់ក្រាបតាងអនុគមន៍

$f(x)=x^3-6x^2+9x$

+ដែនកំណត់ $D=\mathbb{R}$

+ ទិសដៅអថេរភាព: $f'(x)=3x^2-12x+9$

$f'(x)=0$ មានរឹស $x=1$ ឬ $x=3$

+ $\lim\limits_{x\to\pm\infty} f(x)=\lim\limits_{x\to\pm\infty}\left(x^3-6x^2+9x\right)=\pm\infty$

+ តារាងអថេរភាព:

| $x$ | $-\infty$ | | $1$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $4$ | ↘ | $0$ | ↗ | $+\infty$ |



5. ក. រកតម្លៃ $a$ ដើម្បីអោយ $C_a$ ប៉ះនឹងអ័ក្សអាប់ស៊ីស

យើងមាន: $f_a(x) = x^3 - 1 - a(x-1)$

$$f_a'(x) = 3x^2 - a$$

ក្រាប $C_a$ ប៉ះនឹងអ័ក្សអាប់ស៊ីសកាលណា $a = 3,\ a = \dfrac{3}{4}$

ខ. សិក្សាអថេរភាពនិងសង់ក្រាបទៅតាមតម្លៃ $a$

+ ចំពោះ $a = 3$ គេបាន: $f(x) = x^3 - 1 - 3(x-1)$

$f'(x) = 3x^2 - 3,\ f''(x) = 6x$

តារាងអថេរភាព:

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $4$ | $\searrow$ | $0$ | $\nearrow$ | $+\infty$ |

+ ចំពោះ $a = \dfrac{3}{4}$ គេបាន: $f(x) = x^3 - 1 - \dfrac{3}{4}(x-1)$

$f'(x) = 3x^2 - \dfrac{3}{4},\ f''(x) = 6x$

តារាងអថេរភាព:

| $x$ | $-\infty$ | | $-\frac{1}{2}$ | | $\frac{1}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $0$ | $\searrow$ | $-\frac{1}{2}$ | $\nearrow$ | $+\infty$ |

( អ្នកអានសង់ខ្សែកោងខ្លួនឯង )

6. ក. បង្ហាញថា $A(-1,\ 0)$ ជាចំណុចប្រសព្វរវាងក្រាប $C$ និងបន្ទាត់ $L: y = a(x+1)$

យើងមានៈ $y = x^3 - x$ យើងបានៈ $x^3 - x = a(x+1)$

ចំពោះ $A(-1, 0)$ នោះ $0 = 0$ (ពិត)

ខ. រកសមីការបន្ទាត់ប៉ះនឹងក្រាប $C$ ត្រង់ចំណុច $A$

តាមរូបមន្តៈ $y = a'(x - x_0) + y_0$ ដែល

$a' = y'(-1) = 2,\ y_0 = y(0) = 0$ យើងបានៈ

$$y = 2(x+1)$$

គ. រកតម្លៃ $a$ ដើម្បីងោយ $L$ កាត់ $C$ ត្រង់ពីរចំណុចផ្សេងគ្នា $M_1$ និង $M_2$ ក្រៅពី $A$

សមីការអាប់ស៊ីសចំណុចប្រសព្វរវាង $L$ និង $C$

$x^3 - x = a(x+1) \Leftrightarrow (x+1)(x^2 - x - a) = 0$ (1)

$\Leftrightarrow x+1 = 0 \Rightarrow x = -1$ ជាអាប់ស៊ីសរបស់ $A$

ឬ $x^2 - x - a = 0$, មាន $\Delta = 1 + 4a$

ដើម្បីអោយ L កាត់ក្រាប $C$ ត្រង់ពីរចំណុចផ្សេងគ្នា

លុះត្រាតែ $\Delta > 0$ រឺ $1 + 4a > 0 \Rightarrow \boxed{a > -\frac{1}{4}}$

+ រកសំនុំចំណុចកណ្តាល $I$ នៃអង្កត់ $[M_1M_2]$.

តាម(1)បន្ទាត់ $(L)$ កាត់ $C$ កាលណា $a > \frac{1}{4}$ គេបានៈ

អាប់ស៊ីសនៃ $I$ គឺ $x_I = \frac{x_1 + x_2}{2} = \frac{s}{2} = -\frac{b}{2a} = \frac{1}{2}$

នោះ $y_I = a\left(\frac{1}{2}+1\right) = \frac{2}{3}a$ នាំអោយ $a = \frac{2}{3}y_I$

ដោយ $a >= \frac{1}{4}$ គេបាន: $\frac{2}{3}y_I > -\frac{1}{4} \Rightarrow y_I > \frac{3}{8}$

ដូចនេះ **សំណុំចំណុច $I$ ជាបន្ទាត់ $x = \frac{1}{2}$ ផ្នែក $y > \frac{3}{8}$**

7. សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍:

ក. $y = x^4 + 2x^2 - 3$

+ដែនកំណត់ $D = \mathbb{R}$

+ ទិសដៅអថេរភាព: $y' = 4x^3 + 4x$

$y' = 0$ មានរឹស $x = 0$ តែមួយគត់

+ លីមីត $\lim_{x \to \pm\infty}\left(x^4 + 2x^2 - 3\right) = +\infty$

+ តារាងអថេរភាព:

| $x$ | [illegible] | $0$ | [illegible] |
|---|---|---|---|
| $y'$ | $-$ | $0$ | $+$ |
| $y$ | [illegible] ↘ | $3$ | ↗ [illegible] |

+ ក្រាប:

•ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស: បើ $x = 0$

គេបាន: $y = -3$ បើ $y = 0$ គេបាន: $x^4 + 2x^2 - 3 = 0$

មានរឹស $x = \pm\sqrt{3}$

•អ័ក្សឆ្លុះ អ័ក្សអរដោណេជាអ័ក្សឆ្លុះនៃក្រាប។

•សង់ក្រាប:

(ចំពោះសំនួរ ខ. ដល់ ឃ.
សូមអ្នកសិក្សាដោយស្លួនឯងតាម
របៀបខាងលើនិងតាមការណែនាំ
នៅក្នុងសៀវភៅពុម្ព)។



8. ក. រកតម្លៃ $m$ ដើម្បីអោយក្រាបមានចំណុចរបត់ពីរ

គេមាន: $f(x)=x^4-mx^2+3$

$\Rightarrow f'(x)=4x^3-2mx$

ដើម្បីអោយក្រាបនៃអនុគមន៍នេះមានចំណុចរបត់ពីរលុះត្រា តែ $f'(x)=0$ មានរឹសបីផ្សេងគ្នារឺ $-m<0\Rightarrow \boxed{m>0}$

ខ. រកតម្លៃ $m$ ដើម្បីអោយក្រាបគ្មានចំណុចរបត់ក្រាបនៃអនុគមន៍គ្មានចំណុចរបត់កាលណា

$\frac{b}{a}\geq 0\Leftrightarrow -m\geq 0\Rightarrow \boxed{m\leq 0}$

9. គេមាន: $y=\frac{1}{2}x^4-3x^2+\frac{3}{2}$

$\Rightarrow y'=2x^3-6x$ បើ $y'=0$ គេបាន

$2x^3-6x=0$ មានរឹស $x=0$ ឬ $x=\pm\sqrt{3}$

ក. សង់តារាងអថេរភាពនៃអនុគមន៍នេះ:



+ រកចំណុចរបត់នៃក្រាប $C$

$y'' = 6x^2 - 6$ បើ $y'' = 0$ នោះ $6x^2 - 6 = 0$ មានរឹសពីរ $x = \pm 1$ ។ ដូចនេះក្រាបនៃអនុគមន៍មានចំណុចរបត់ពីរគឺ $(-1; -1)$ និង $(1; -1)$

ខ. រកសមីការបន្ទាត់ប៉ះត្រង់ចំណុចរបត់:

+ ចំពោះចំណុច $(-1; -1)$ មានសមីការ

$y = y'(-1)(x+1) - 1$ ដែល

$y'(-1) = 4 \Rightarrow y = 4(x+1) - 1$ រឺ $\boxed{y = 4x + 3}$

+ ចំពោះចំណុច $(1; -1)$ មានសមីការ

$y = y'(1)(-1) - 1$ ដែល $y'(1) = -4$

$\Rightarrow y = -4(x-1) - 1$ រឺ $\boxed{y = -4 + 3}$

គ. សង់បន្ទាត់ប៉ះនឹងក្រាប $C$



ឃ. រកសមីការបន្ទាត់ដែលកាត់តាម $A(0, \frac{3}{2})$ ហើយប៉ះនឹងក្រាប $C$ :យើងមាន: $y = y'(0)(x - 0) + \dfrac{3}{2}$

តែ $y'(0) = 0$ នោះ: $y = \dfrac{3}{2}$

10. រកតម្លៃ $m$

គេមាន: $f(x)=-x^4+2mx^2-2m+1$

ដើម្បីអោយ $f$ មានអតិបរមាធៀបពីរនិងអប្បបរមាធៀបមួយ

លុះត្រាតែ $\frac{2m}{-1}<0 \Rightarrow m>0$

ខ. សិក្សាអថេរភាពនិងសង់ក្រាបតាងអនុគមន៍ $f$

ចំពោះ $m=5$ យើងបាន: $f(x)=-x^4+10x^2-9$

$\Rightarrow f'(x)=-4x^3+20x$ បើ $f'(x)=0$ គេបាន

$x=0$ ឬ $x=\pm\sqrt{5}$

តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | $-\sqrt{5}$ | | $0$ | | $\sqrt{5}$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | ↗ | $16$ | ↘ | $-9$ | ↗ | $16$ | ↘ | $-\infty$ |

\+ ក្រាប:

• ចំណុចក្រាបកាត់អ័ក្ស: បើ $x=0$

គេបាន: $y=-9$ បើ $y=0$ នោះ: $x=\pm1, x=\pm3$



ឆ. រកតម្លៃ $m$ ដើម្បីអោយក្រាប $C_m$ កាត់អ័ក្សអាប់ស៊ីសត្រង់បួនចំណុចផ្សេងគ្នា

ក្រាបកាត់អ័ក្សអាប់ស៊ីសត្រង់បួនចំណុចផ្សេងគ្នា កាលណាសមីការ: $-x^4+2mx^2-2m+1=0$ (1) មានរឹសបួនផ្សេងគ្នា។ តាង $t=x^2, t\geq 0$

យើងបាន: $-t^2+2mt-2m+1=0$ (2)

$$\Delta' = m^2-2m+1$$

(1) មានរឹសបួនផ្សេងគ្នាកាលណា (2) មានរឹសពីរផ្សេងគ្នា

$\Rightarrow \Delta' > 0 \Leftrightarrow m^2-2m+1>0$

| $m$ | | 1 | |
|---|---|---|---|
| $\Delta' > 0$ | − | 0 | + |

ដូចនេះ: $\boxed{m>1}$

11. បង្ហាញថាបន្ទាត់ដែលបានអោយគឺជាអាស៊ីមតូតនៃក្រាបតាង $f$ :

ក. $f(x)=\dfrac{2x+1}{x}$ គេបាន:

+ $\lim\limits_{x\to 0} f(x)=\infty$ នាំអោយ $L_1: x=0$ ជាអាស៊ីមតូតឈរនៃក្រាបតាង $f$

+ $\lim\limits_{x\to\pm\infty} f(x) = 2$ នោះ $L_2 : y = 2$ ជាអាស៊ីមតូតដេកនៃ

ក្រាបតាង $f$ ។

ខ. $f(x) = \dfrac{-3x+1}{x+2}$ គេបាន:

+ $\lim\limits_{x\to-2} f(x) = \lim\limits_{x\to-2} \dfrac{-3x+1}{x+2} = \infty$

+ $\lim\limits_{x\to\pm\infty} f(x) = \lim\limits_{x\to\pm\infty} \dfrac{-3x+1}{x+2} = -3$

ដូចនេះ បន្ទាត់ $L_1 : x = -2$ និងបន្ទាត់ $L_2 : y = -3$

ជាអាស៊ីមតូតឈរនិងដេករៀងគ្នានៃក្រាបតាង $f$ ។

12. សិក្សាអថេរភាពនិងសង់ក្រាបតាងអនុគមន៍

ក. $y = \dfrac{1}{x-3}$

+ដែនកំណត់ $D = \mathbb{R} - \{3\}$

+ ទិសដៅអថេរភាព: $y' = -\dfrac{1}{(x-3)^2} < 0,\ x \in D$

+ $\lim\limits_{x\to3^+} f(x) = +\infty,\ \lim\limits_{x\to3^-} f(x) = -\infty$

នាំ[illegible]យបន្ទាត់ $x = 3$ ជាអាស៊ីមតូតឈរ

+ $\lim\limits_{[illegible]} f(x) = 0$ នាំអោយបន្ទាត់ $y = 0$ ជាអាស៊ីមតូតដេក

+ [illegible]

| $x$ | $-\infty$ | 3 | $+\infty$ |
| --- | --- | --- | --- |
| $y'$ | $-$ | ‖ | $-$ |
| $y$ | $0 \searrow -\infty$ | ‖ | $+\infty \searrow 0$ |

+ ក្រាប:

• ចំណុចក្រាបកាត់អ័ក្ស: បើ $x=0,\ y=-\dfrac{1}{3}$




(ចំពោះសំនួរខ. ដល់ ឆ. សូមអ្នកអានសិក្សាដោយខ្លួនឯង តាមលំនាំខាងលើនិង តាមការណែនាំនៅក្នុងសៀវភៅពុម្ព)។

13. ក. រកមេគុណ $a, b, c$ និង $d$

យើងមាន: $f(x)=\dfrac{ax+b}{cx+d}$ មានក្រាប $H$ ។

ដោយក្រាបកាត់ $H$ តាមចំណុច $E(-3,-1); F(0,5)$ និង-$G(3,2)$ យើងបាន:

$$\begin{cases} -3a+b=3c-d & (1) \\ b=5d & (2) \\ 3a+b=3c+d & (3) \end{cases}$$

ដោយដោះស្រាយប្រព័ន្ធនេះគេបាន:

$$\boxed{a=1,\ b=5,\ c=1,\ d=1}$$

ខ. រកមេគុណ $a, b, c$ និង $d$

$$\boxed{a=2,\ b=-2,\ c=1,\ d=-2}$$

14. ក. រកមេគុណ $b, c, d$

គេមាន: $y=f(x)=\dfrac{x+b}{cx+d}$ មានក្រាប $H$

ដើម្បីអោយក្រាប $H$ កាត់អ័ក្សអាប់ស៊ីសត្រង់ $x=-1$ កាត់អ័ក្សអរដោនេត្រង់ $y=-1$ និងកាត់តាម $A(2, 3)$ លុះត្រាតែ

$$\begin{cases} f(-1)=0 \\ f(0)=-1 \\ f(2)=3 \end{cases} \Leftrightarrow \begin{cases} \frac{-1+b}{-c+d}= \\ \frac{b}{d}=3 \\ \frac{2+b}{2c+d}=3 \end{cases} \Leftrightarrow \begin{cases} b=1 \\ d=-b=-1 \\ c=1 \end{cases}$$

ដូចនេះ: $\boxed{b=1,\ c=1,\ d=-1}$

ខ. សិក្សាអថេរភាពនិងសង់ក្រាប $H$ នៃ $f$

ចំពោះ: $b=c=1,\ d=-1$ យើងបាន:

$f(x)=\dfrac{x+1}{x-1}$

+ដែនកំណត់ $D=\mathbb{R}-\{1\}$

+ ទិសដៅអថេរភាព: $f'(x)=-\dfrac{2}{(x-1)^2}<0$

+ $\lim\limits_{x\to\pm\infty} f(x)=\lim\limits_{x\to\pm\infty}\dfrac{x+1}{x-1}=1$ នាំអោយបន្ទាត់ $y=1$ ជាអាស៊ីមតូតដេក។

+ $\lim\limits_{x\to 1^-} f(x)=\lim\limits_{x\to 1^-}\dfrac{x+1}{x-1}=-\infty$

+ $\lim\limits_{x\to 1^+} f(x)=\lim\limits_{x\to 1^+}\dfrac{x+1}{x-1}=+\infty$

នាំអោយបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរ។

+ តារាងអថេរភាព:

| $x$ | $-\infty$ | $1$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $-$ | ‖ | $-$ |
| $f(x)$ | $1 \searrow -\infty$ | ‖ | $+\infty \searrow 1$ |

+ ក្រាប

ចំណុចក្រាបកាត់អ័ក្ស: បើ $x=0$, $y=-1$

បើ $y=0$ នោះ $x=-1$

គ. កំណត់ចំណុចប្រសព្វរវាងក្រាប $H$ និងបន្ទាត់ $y=x$

សមីការអាប់ស៊ីសចំណុចប្រសព្វ $x=\dfrac{x+1}{x-1}$

$\Leftrightarrow x^2-2x-1=0$ មានរឹស $x=1\pm\sqrt{2}$

+ ចំពោះ $x=1+\sqrt{2}$ គេបាន $y=1+\sqrt{2}$

+ ចំពោះ $x=1-\sqrt{2}$ គេបាន $y=1-\sqrt{2}$

15. ក. សិក្សាអថេរភាពនិងសង់ក្រាប $H_1$ ចំពោះ $p=1$

ចំពោះ $p=1$ យើងបានៈ $y=f(x)=\dfrac{2x+1}{x-1}$

+ ដែនកំណត់ $D=\mathbb{R}-\{1\}$

+ ទិសដៅអថេរភាព $f'(x)=\dfrac{-3}{(x-1)^2}<0,\forall x\in D$

+ $\lim\limits_{x\to1^+} f(x)=+\infty,\ \lim\limits_{x\to1^-} f(x)=-\infty$

នាំអោយបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរ។

+ $\lim\limits_{x\to\pm\infty} f(x)=\lim\limits_{x\to\mp\infty}\dfrac{2x+1}{x-1}=2$

នាំអោយបន្ទាត់ $y=2$ ជាអាស៊ីមតូតដេក។



+ តារាងអថេរភាព:

| $x$ | $-\infty$ | | 1 | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | ‖ | $-$ | |
| $y$ | 2 ↘ | $-\infty$ | ‖ | $+\infty$ ↘ | 2 |

+ ចំណុចប្រសព្វកាត់អ័ក្ស: បើ $x=0$ នោះ $y=-1$

បើ $y=0$ នោះ $x=-\dfrac{1}{2}$




ខ. រកកូអរដោនេនៃចំណុចប៉ះ $A$ រវាងក្រាប $H_1$ និងបន្ទាត់ដែលមានមេគុណប្រាប់ទិសស្មើ $-\dfrac{1}{3}$

យើងបាន: $f'(x)=-\dfrac{1}{3}\Leftrightarrow -\dfrac{3}{(x-1)^2}=-\dfrac{1}{3}$

$\Leftrightarrow x^2-2x-8=0 \Leftrightarrow x=4$ ឬ $x=-2$

• ចំពោះ: $x=4$ គេបាន: $y=3$

•ចំពោះ $x=-2$ គេបាន: $y=\frac{5}{3}$

ដូចនេះ: កូអរដោនេចំណុច $A$ គឺ $(4,3)$ រឺ $\left(-2,\frac{5}{3}\right)$

គ. រកសមីការអាស៊ីមតូតទាំងពីរនៃក្រាប $H_p$

យើងមាន: $+\lim_{x\to p} f(x)=\lim_{x\to p}\frac{2px+1}{x-p}=\infty$

នោះបន្ទាត់ $x=p$ ជាអាស៊ីមតូតឈរនៃ $H_p$

$+\lim_{x\to\infty} f(x)=\lim_{x\to\infty}\frac{2px+1}{x-p}=2p$

នោះបន្ទាត់ $y=2p$ ជាអាស៊ីមតូតដេកនៃ $H_p$

•រកសំណុំចំណុចនៃចំណុចប្រសព្វរវាងអាស៊ីមតូតទាំងពីរ

សំណុំចំណុចប្រសព្វរវាងអាស៊ីមតូតទាំងពីរគឺ $M_p(p,2p)$

<u>ជំពូកទី៦</u> <u>ប្រូបាប</u>

<u>មេរៀនទី១</u>

ប្រូបាប

<u>លំហាត់</u>

1. ក. គេបោះកាក់មួយនិងគ្រាប់ឡុកឡាក់មួយគ្រាប់ព្រមគ្នា។ ចូរកំណត់:

ក. សកម្មភាពដែលជាពិសោធន៍ចៃដន្យ និងជាវិញ្ញាសា

ខ. លំហសំណាក $S$ និង

ព្រឹត្តិការណ៍ $A$ "បោះកាក់បានខាងរូប $H$"

ព្រឹត្តិការណ៍ $B$ "បោះគ្រាប់ឡុកឡាក់បានខាងលេខ..."

គ. រកប្រូបាបព្រឹត្តិការណ៍ផ្ទុយនឹង $A$ ព្រឹត្តិការណ៍នឹង $B$ និងព្រឹត្តិការណ៍ផលគុណ $A$ និង $B$ ។

2. គេហូតបៀមួយសន្លឹកដោយចៃដន្យចេញពីហ៊ូបៀ 52 សន្លឹក។ រកប្រូបាបដែលហូតបានៈ

ក. សន្លឹកអាត់ ខ. សន្លឹកក្រហម គ. សន្លឹកអាត់ ឬ ក្រហម

ឃ. មិនមែនអាត់ និងមិនមែនក្រហម។

3. ថង់មួយមានឃ្លី 10 ចុះលេខពី 0 ដល់ 9 ។ គេចាប់យកឃ្លីមួយដោយចៃដន្យ។ ចូរកំណត់:

ក. លំហសំណាក $S$ និង

ព្រឹត្តិការណ៍ $A$ "ចាប់បានឃ្លីមានលេខជាពហុគុណនៃ3"

ព្រឹត្តិការណ៍ $B$ "ចាប់បានឃ្លីមានលេខធំជាង5"

ខ. រកប្រូបាបនៃព្រឹត្តិការណ៍ $A, B, A \cap B$ និង $A \cap B$

4. ថង់មួយមានឃ្លីខៀវ 7 និងឃ្លីស 3។ គេចាប់យកឃ្លីម្តង 3 ដោយចៃដន្យតែម្តងគត់។ រកប្រូបាបដែលចាប់បាន:

ក. ឃ្លីខៀវ 2 និងឃ្លីស1 ខ. ឃ្លីខៀវទាំង3 គ. ឃ្លីសទាំង3

5. គេបោះគ្រាប់ឡុកឡាក់ 2ព្រមគ្នាមួយពណ៌ក្រហម។

រកប្រូបាបដែលៈ

ក. លេខចេញលើគ្រាប់ខៀវ ស្មើនឹង 2 ដងនៃលេខចេញលើគ្រាប់ក្រហម។

ខ. ផលបូកលេខគ្រាប់ឡុកឡាក់ទាំង 2 ស្មើនឹង 5 ។

6.ក្នុងប្រអប់1មានក្រដាសបត់ជាសន្លឹកឆ្នោតចាប់យករង្វាន់។ សន្លឹកឆ្នោតមាន20 សន្លឹកដែលឆ្នោតត្រូវរង្វាន់មាន12 សន្លឹក សម្រាប់សិស្ស 20 នាក់ចាប់យកមួយសន្លឹកម្នាក់បន្តបន្ទាប់គ្នា ដើម្បីផ្ទៀងមើលរង្វាន់រៀងៗខ្លួន។ សុខជាអ្នកចាប់បានមុនគេ បន្ទាប់សៅចាប់ទី 2 និងសនចាប់ទី 3 និងសិស្សឯទៀតចាប ម្នាក់មួយបន្តបន្ទាប់គ្នារហូតអស់ឆ្នោត។រកប្រូបាបដែលៈ

ក. សុខចាប់បានឆ្នោត្រូវរង្វាន់

ខ. សៅចាប់បានឆ្នោតត្រូវរង្វាន់

គ. សនចាប់បានឆ្នោត្រូវរង្វាន់

ឃ. តើអ្នកចាប់មុន និងអ្នកចាប់ក្រោយអ្នកណាមានសំណាងជាងអ្នកណា ?

## ដំណោះស្រាយ

1. ក. ពីសោធន៍ចៃដន្យគឺ សម្មភាពបោះកាក់និងគ្រាប់ឡុកឡាក់។

+ វិញ្ញាសាគឺសកម្មភាពបោះកាក់មួយនិង គ្រាប់ឡុកឡាក់មួយគ្រាប់ព្រមគ្នា។

ខ. លំហសំណាក $S=\{(1,H);(2,H);(3,H);(4,H);$
$(5,H);(6,H);(1,T);(2,T);(3,T);(4,T);$
$(5,T);(6,T)\}$ ។

+ ព្រឹត្តិការណ៍:

$A=\{(1,H);(2,H);(3,H);(4,H);(5,H);(6,H)\}$ +

ព្រឹត្តិការណ៍:

$B=\{(4,H);(4,T)\}$ ។

គ. រកប្រូបាបព្រឹត្តិការណ៍ផ្ទុយនឹង $A$

យើងមានៈ $P(A)=\dfrac{n(A)}{n(S)}=\dfrac{6}{12}=\dfrac{1}{2}$

$\Rightarrow P\left(\overline{A}\right)=1=P(A)=1-\dfrac{1}{2}=\dfrac{1}{2}$

+ រកប្រូបាបព្រឹត្តិការណ៍ផ្ទុយនឹង $B$

យើងមានៈ $P(B)=\dfrac{n(B)}{n(S)}=\dfrac{2}{12}=\dfrac{1}{6}$

$\Rightarrow P\left(\overline{B}\right)=1-\dfrac{1}{6}=\dfrac{5}{6}$

+ រកប្រូបាបព្រឹត្តិការណ៍ផលគុណ $A$ និង $B$

$$P(A \cap B) = P(A) \times P(B) = \frac{1}{2} \times \frac{1}{6} = \frac{1}{12}$$

2. រកប្រូបាបដែលហូតបាន:

ក. សន្លឹកអាត់

ដោយក្នុងបៀរហ៊ូ 52 សន្លឹកមានអាត់ 4 សន្លឹក

យើងបាន: $P_{(\text{អាត់})} = \frac{4}{52} = \frac{1}{13}$

ខ. សន្លឹកក្រហម

ដោយក្នុងបៀរហ៊ូ 52 សន្លឹកមានសន្លឹកក្រហម 26 សន្លឹក

យើងបាន: $P_{(\text{ក្រហម})} = \frac{26}{52} = \frac{1}{2}$

គ. សន្លឹកអាត់ ឬ ក្រហម

ដោយក្នុងសន្លឹកក្រហម 26 សន្លឹកមានអាត់ 2 សន្លឹកដែលជាសន្លឹកក្រហម យើងបាន:

$$P_{(\text{អាត់ ឬ ក្រហម})} = \frac{1}{13} + \frac{1}{2} - \frac{2}{52} = \frac{28}{52} = \frac{7}{13}$$

3. ក. កំណត់:

+ លំហសំណាក $S = \{0,1,2,3,4,5,6,7,8,9\}$

+ ព្រឹត្តិការណ៍ $A$ "ចាប់បានឃ្លីមានលេខជាពហុគុណនៃ3"

លេខជាពហុគុណនៃ 3មាន $0,3,6,9$

ដូចនេះ: $\boxed{A=\{0,3,6,9\}}$

+ ព្រឹត្តិការណ៍ $B=\{6,7,8,9\}$

ខ. រកប្រូបាបនៃព្រឹត្តិការណ៍ $A,B,A\cap B$ និង $A\cap B$

យើងបាន: $P(A)=\dfrac{n(B)}{n(S)}=\dfrac{4}{10}=\dfrac{2}{5}$

$$P(B)=\frac{n(B)}{n(S)}=\frac{4}{10}=\frac{2}{5}$$

$$P(A\cap B)=\frac{n(A\cap B)}{n(S)}=\frac{2}{10}=\frac{1}{5}$$

$$P(A\cap B)=P(A)+P(B)-P(A\cap B)=\frac{3}{5}$$

4. រកប្រូបាបដើម្បីអោយបាន:

ក. ឃ្លីខៀវ 2 និង ឃ្លីមួយ

តាង $A$ ជាព្រឹត្តិការណ៍នេះ យើងបាន:

$P(A)=\dfrac{n(A)}{n(S)}$ ដែល $n(A)=C(7,2)\times C(3,1)$ រី

$n(A)=\dfrac{7!}{5!2!}\times\dfrac{3!}{2!1}=63$ ហើយ

$$n(S)=C(10,3)=\frac{10!}{7!3!}=120$$

$$\Rightarrow P(A)=\frac{63}{120}=0.525$$

ខ. ឃ្លីខៀវទាំងបី

តាង $B$ ជាព្រឹត្តិការណ៍នេះ យើងបាន:

$$P(B)=\frac{n(B)}{n(S)} \text{ ដែល } n(B)=C(7,3)=35$$

$$\Rightarrow P(B)=\frac{35}{120}=0.921$$

គ. ឃ្លីសទាំងបី: តាង $C$ ជាព្រឹត្តិការណ៍នេះ

យើងបាន: $P(C)=\frac{n(C)}{n(S)}$ ដែល $n(C)=C(3,3)=1$

$$\Rightarrow P(C)=\frac{1}{120}=0.0083$$

5. រកប្រូបាបដែល:

ក. លេខចេញលើគ្រាប់ខៀវស្មើនឹងពីរដងនៃលេខចេញលើ
គ្រាប់ក្រហម:

តាង $A$ ជាព្រឹត្តិការណ៍នេះ យើងបាន:

$A=\{(a,b)$ ដែល $a$ ជាលេខចេញលើគ្រាប់ឡុកឡាក់ខៀវ ហើយ $b$ ជាលេខចេញលើគ្រាប់ឡុកឡាក់ក្រហម $\}$ ។

ដូច្នេះ $\boxed{A=\{(2,1);(4,2);(6,3)\}}$

ចំនួនករណីអាច $n(S)=6\times 6=36$

$$\Rightarrow P(A)=\frac{n(A)}{n(S)}=\frac{3}{36}=\frac{1}{12}=0.083$$

ខ. ផលបូកលេខគ្រាប់ឡុកឡាក់ទាំងពីរស្មើ 5

តាង $B$ ជាព្រឹត្តិការណ៍នេះ យើងបាន៖

$B\{(1,4);(2,3);(4,1);(3,2)\}$

$$\Rightarrow P(B)=\frac{n(B)}{n(S)}=\frac{4}{36}=\frac{1}{9}=0.11$$

6. រកប្រូបាបដែល៖

ក. សុខចាប់បានឆ្នោតត្រូវរង្វាន់

តាង $A$ ជាព្រឹត្តិការណ៍នេះ

យើងបាន៖ $P(A)=\frac{n(A)}{n(S)}=\frac{12}{20}=\frac{3}{5}$

ខ. សៅចាប់បានឆ្នោតត្រូវរង្វាន់

តាង $B$ ជាព្រឹត្តិការណ៍នេះ

យើងបាន៖ $P(B)=\frac{12}{20}\times\frac{11}{19}+\frac{8}{20}\times\frac{12}{19}=\frac{3}{5}$

គ. សនចាប់បានឆ្នោតត្រូវរង្វាន់

តាង $C$ ជាព្រឹត្តិការណ៍នេះ៖

យើងបាន: $P(C)=\dfrac{3}{5}$

ឃ. អ្នកចាប់មុននឹងអ្នកចាប់ក្រោយមានសំណាងដូចគ្នា

## ជំពូកទី៧ ស្ថិតិ

### មេរៀនទី១ បំលែងចែកទិន្នន័យជាភាគរយ

#### លំហាត់

1. គណនាទីលទាំងបី និងភាគដប់នៃសំណុំទិន្នន័យនីមួយៗខាងក្រោម:

ក. 1 3 5 5 7 0 8 2 2 4 4

ខ. 7 10 22 2 0 8 12 13 18 21។

2. គណនាកាទីលទីមួយ $Q_1$ កាទីលទីបី $Q_3$ និង $L_{68}$ នៃសំណុំទិន្នន័យ

ក. 18 0 8 16 10 4 4 14 2 13 5 7

ខ. 0.7 0.4 0.65 0.78 0.45 0.32 1.9 0.0078

3. គណនាមេដ្យាន កាទីលទីមួយ $Q_1$ កាទីលទីបី $Q_3$ និង $L_{63}$ នៃបំណែងចែកប្រេកង់ខាងក្រោម:

ក.

| | | | | | | |
|---|---|---|---|---|---|---|
| x | 4 | 5 | 6 | 7 | 8 | 9 |
| y | 12 | 9 | 8 | 13 | 9 | 9 |

ខ.

| | | | | | |
|---|---|---|---|---|---|
| x | 12 | 13 | 14 | 15 | 16 |
| y | 3 | 9 | 11 | 15 | 7 |

4. តារាងខាងក្រោមបង្ហាញពិន្ទុ ដែលបានមកពីបោះគ្រាប់ឡុកឡាក់មួយ ចំនួន 60 ដង។ គណនា $Q_2$ និង $D_1$ ។

| ពិន្ទុ x | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|
| ប្រេកង់ f | 12 | 9 | 8 | 13 | 9 | 9 |

5. អ្នកលក់សៀវភៅម្នាក់បានអោយដឹងថា សៀវភៅថ្មីរបស់គាត់មានទាំងអស់ចំនួន25 ក្បាលក្នុងនោះមានចំនួន4 ក្បាលមួយក្បាលលក់តម្លៃ 10$ មានចំនួន 6 ក្បាលមួយក្បាលលក់តម្លៃ 8$ មានចំនួន 4 ក្បាលមួយលក់តម្លៃ 7$ មានចំនួន 9 ក្បាលមួយក្បាលលក់តម្លៃ 15$ និងមានចំនួន 2 ក្បាលមួយក្បាលលក់តម្លៃ 22$ ។

ក. គណនាតម្លៃមធ្យមក្នុងសៀវភៅមួយក្បាល

ខ. គណនាកាទីល $Q_1, Q_2, Q_3$ និង $L_{32}$ ។

6. ការពិសោធន៍បណ្ដុះកូនប៉េងប៉ោះដោយប្រើជីគីមីក្នុងរយៈពេលមួយអាទិត្យ បម្រែបម្រួលកំពស់កូនប៉េងប៉ោះទទួលបានលទ្ធផលដូចខាងក្រោមៈ

| កំពស់ (mm) | 0-5 | 5-10 | 10-15 | 15-20 | 20-25 | 25-30 | 30-35 |
|---|---|---|---|---|---|---|---|
| ចំនួនកូនប៉េងប៉ោះ f | 3 | 15 | 72 | 15 | 90 | 36 | 8 |

គណនា $Q_1, Q_3$ និង $D_1$ ។

7. គេបានកត់ត្រា ចំនួនសៀវភៅដែលមាននៅតាមធ្នើចំនួន 40 ក្នុងបណ្ណាល័យមួយ។

| ចំនួនសៀវភៅ | 30-35 | 35-40 | 40-45 | 45-50 | 50-55 | 55-60 |
|---|---|---|---|---|---|---|
| ចំនួនធ្នើ | 4 | 6 | 10 | 13 | 5 | 3 |

គណនាមេដ្យាន និង $L_{28}$។

## ដំណោះស្រាយ

1. គណនាកាទីលទាំងបី និងភាគរបំនៃសំណុំទិន្នន័យ:

ក. 1 3 5 5 7 0 8 2 2 4 4

ដំបូងគេត្រូវរៀបទិន្នន័យតាមលំដាប់កើនគឺ:

0 1 2 2 3 4 4 5 5 7 8 យើងបាន:

$+\ Q_1 =$ តម្លៃទី $\frac{1}{4}(n+1)$ ដែល $n=11$

$=$ តម្លៃទី $\frac{1}{4}(n+1) =$ តម្លៃទី3

ដូច្នេះ $\boxed{Q_1 = 2}$

$+\ Q_2 =$ តម្លៃទី $\frac{1}{2}(n+1) =$ តម្លៃទី 6

ដូច្នេះ $\boxed{Q_2 = 4}$

$+\ Q_3 =$ តម្លៃតួទី $\frac{3}{4}(n+1) =$ តម្លៃទី 9

ដូច្នេះ $\boxed{Q_3 = 5}$

+ $D_1 =$ តម្លៃតួទី $\frac{1}{10}(n+1) =$ តម្លៃទី 1.2

ដោយតួទី 1.2 នៅចន្លោះតួទី 1 និងតួទី 2 គេបាន:

$D_1 = \frac{0+1}{2} = \frac{1}{2}$ ដូច្នេះ $\boxed{D_1 = \frac{1}{2}}$

ខ. 7 10 22 2 0 8 12 13 18 21

ដំបូងគេត្រូវរៀបទិន្នន័យតាមលំដាប់កើនគឺ:

0 2 7 8 10 12 13 18 21 22, $n = 10$

គេបាន: $Q_1 =$ តម្លៃតួទី $\frac{1}{4}(n+1) =$ តម្លៃតួទី 2.75

ដោយតួទី 2.75 នៅចន្លោះតួទី 2 និងតួទី 3 គេបាន:

$$Q_1 = \frac{2+7}{2} = \frac{9}{2} = 4.5$$

ដូច្នេះ $\boxed{Q_1 = 4.5}$

+ $Q_2 =$ តម្លៃតួទី $\frac{1}{2}(n+1) =$ តម្លៃទី 5.5

ដោយតួទី 5.5 នៅចន្លោះតួទី 5 និងតួទី6 គេបាន:

$Q_2 = \frac{10+12}{2} = 11$ ដូច្នេះ $\boxed{Q_2 = 11}$

$+\ Q_3 =$ តម្លៃតួទី $\frac{3}{4}(n+1) =$ តម្លៃទី 8.25

ដោយតួទី 8.25 នៅចន្លោះតួទី 8 និងតួទី9 គេបាន:

$Q_3 = \frac{18+21}{2} = 19.5$ ដូច្នេះ $\boxed{Q_3 = 19.5}$

$+\ D_1 =$ តម្លៃតួទី $\frac{1}{10}(n+1) =$ តម្លៃទី 1.1

ដោយតួទី 1.1 នៅចន្លោះតួទី 1 និងតួទី 2 គេបាន:

$D_1 = \frac{0+2}{2} = 1$ ដូច្នេះ $\boxed{D_1 = 1}$

2\. គណនាកាទីលទីមួយ $Q_1$ និងកាទីលទីបី $Q_3$ និង $L_{68}$

ក. 0 2 4 4 5 7 8 10 13 14 16 18

គេបាន: $Q_1 =$ តម្លៃតួទី $\frac{1}{4}(n+1), n = 12$

$=$ តម្លៃទី $\frac{1}{4}(n+1) =$ តម្លៃទី 3.25

$\Rightarrow Q_1 = \frac{4+4}{2} = \frac{8}{2} = 4$ ដូច្នេះ $\boxed{Q_1 = 4}$

$+\ Q_3 =$ តម្លៃតួទី $\frac{3}{4}(n+1) =$ តម្លៃទី 9.75

$\Rightarrow Q_3 = \frac{13+14}{2} = 13.5$ ដូច្នេះ $\boxed{Q_3 = 13.5}$

+ $L_{68} =$ តម្លៃតួទី $\frac{68}{100}(n+1) =$ តម្លៃតួទី 8.84

$\Rightarrow L_{68} = \frac{10+13}{2} = 11.5$ ដូចនេះ $\boxed{L_{68} = 11.5}$

ខ. $0.0078; 0.32; 0.4; 0.45; 0.65; 0.7; 0.78; 1.9, n = 8$

+ $Q_1 =$ តម្លៃតួទី $\frac{1}{4}(8+1) =$ តម្លៃតួទី 2.25

$\Rightarrow Q_1 = \frac{0.32+0.4}{2} = 0.36$ ដូច្នេះ $\boxed{Q_1 = 0.36}$

+ $Q_3 =$ តម្លៃតួទី $\frac{3}{4}(8+1) =$ តម្លៃទី 6.75

$\Rightarrow Q_3 = \frac{0.7+0.78}{2} = 0.74$ ដូច្នេះ $\boxed{Q_3 = 0.74}$

+ $L_{68} =$ តម្លៃតួទី $\frac{68}{100}(8+1) =$ តម្លៃតួទី 6.12

ដូចនេះ $\boxed{L_{68} = 0.74}$

3. គណនាមេដ្យាន $Q_1$, $Q_3$ និង $L_{63}$ នៃៈ

ក. សង់តារាងប្រេកង់កើន

| x | f | f ↗ |
|---|---|---|
| 4 | 12 | 12 |
| 5 | 9 | 21 |
| 6 | 8 | 29 |
| 7 | 13 | 42 |
| 8 | 9 | 51 |
| 9 | 9 | 60 |

យើងបាន: $(n = 60)$

+ មេដ្យាន = តម្លៃតួទី $\frac{1}{2}(60+1) =$ តម្លៃតួទី 30.5

ដូច្នេះ មេដ្យានស្មើនឹង 7

+ $Q_1 =$ តម្លៃតួទី $\frac{1}{4}(60+1) =$ តម្លៃតួទី 15.25

ដូច្នេះ $Q_1 = 5$

+ $Q_3 =$ តម្លៃតួទី $\frac{3}{4}(60+1) =$ តម្លៃទី 45.75

ដូច្នេះ $Q_3 = 8$

+ $L_{63} =$ តម្លៃតួទី $\frac{63}{100}(60+1) =$ តម្លៃតួទី 38.43

ដូចនេះ $L_{63} = 7$

ខ. សង់តារាងប្រេកង់កើន:

| x | f | f ↗ |
|---|---|---|
| 12 | 3 | 3 |
| 13 | 9 | 12 |
| 14 | 11 | 23 |
| 15 | 15 | 38 |
| 16 | 7 | 45 |

យើងបាន: $(n = 45)$

+ មេដ្យាន $=$ តម្លៃតួទី $\frac{1}{2}(45+1)=$ តម្លៃតួទី 23

ដូច្នេះ **មេដ្យានស្មើនឹង 14**

+ $Q_1 =$ តម្លៃតួទី $\frac{1}{4}(45+1)=$ តម្លៃតួទី 11.5

ដូច្នេះ $\boxed{Q_1 = 13}$

+ $Q_3 =$ តម្លៃតួទី $\frac{3}{4}(45+1)=$ តម្លៃទី 34.5

ដូច្នេះ $\boxed{Q_3 = 15}$

+ $L_{63} =$ តម្លៃតទី $\frac{63}{100}(45+1)=$ តម្លៃតួទី 28.98

ដូចនេះ $\boxed{L_{63} = 15}$

4. គណនា $Q_2$ និង $D_1$

សង់តារាងប្រេកង់កើននៃទិន្នន័យ:

| x | f | $f\nearrow$ |
|---|---|---|
| 1 | 12 | 12 |
| 2 | 9 | 21 |
| 3 | 8 | 29 |
| 4 | 13 | 42 |
| 5 | 9 | 51 |
| 6 | 9 | 60 |

យើងបាន: $(n=60)$

+ $Q_2 =$ តម្លៃតួទី $\frac{1}{2}(60+1)=$ តម្លៃតួទី 30.5

$\boxed{\Rightarrow Q_2 = 1}$

$+\ D_1 =$ តម្លៃតួទី $\frac{1}{10}(60+1) =$ តម្លៃតួទី 6.1

ដូច្នេះ $\boxed{D_1 = 1}$

5. ក. គណនាតម្លៃមធ្យមក្នុងសៀវភៅ 1 ក្បាល

បង្កើតតារាងប្រេកង់កើន:

| តម្លៃសៀវភៅ x | ចំនួនសៀវភៅ f | $f^{\nearrow}$ |
|---|---|---|
| \$7 | 4 | 4 |
| \$8 | 6 | 10 |
| \$10 | 4 | 14 |
| \$15 | 9 | 23 |
| \$22 | 2 | 25 |

តាង $\overline{X}$ ជាតម្លៃមធ្យមក្នុងសៀវភៅ 1 ក្បាល

$$\overline{X} = \frac{(7\times4)+(8\times6)+(10\times4)+(15\times9)+(22\times2)}{25}$$

$$= \frac{28+48+40+135+44}{25} = 11.8$$

ដូចនេះ $\boxed{\overline{X} = 11.8\$}$

ខ. គណនា $Q_1, Q_2, Q_3$ និង $L_{32}$ $(n = 25)$

$+\ Q_1 =$ តម្លៃតួទី $\frac{1}{4}(25+1) =$ តម្លៃទី 6.5

ដូច្នេះ $\boxed{Q_1 = \$8}$

+ $Q_2 =$ តម្លៃតួទី $\frac{1}{2}(25+1) =$ តម្លៃទី 13

ដូចនេះ $\boxed{Q_2 = \$10}$

+ $Q_3 =$ តម្លៃតួទី $\frac{3}{4}(25+1) =$ តម្លៃទី 19.5

ដូច្នេះ $\boxed{Q_3 = \$15}$

+ $L_{32} =$ តម្លៃតួទី $\frac{32}{100}(25+1) =$ តម្លៃតួទី 8.32

ដូចនេះ $\boxed{L_{32} = \$8}$

6. គណនា $Q_1, Q_3$ និង $D_1$

បង្កើតតារាងប្រេកង់កើន

| កំពស់ (mm) | ចំនួនកូនប៉េងពោះ f | $f \nearrow$ |
|---|---|---|
| 0-5 | 3 | 3 |
| 5 - 10 | 15 | 18 |
| 10 - 15 | 72 | 90 |
| 15 - 20 | 15 | 105 |
| 20 - 25 | 90 | 195 |
| 25 - 30 | 36 | 231 |
| 30 - 35 | 8 | 239 |

ចំពោះ $Q_1$ និង $Q_3$ យើងអនុវត្តន៍រូបមន្ត:

+ $Q_1 = L + \frac{\frac{1}{4}n - f^{\uparrow}}{f} \times i$ ដែល $n = 239$

ដែល $Q_1 =$ តម្លៃតួទី $\frac{1}{4}n =$ តម្លៃតួទី 59.75

$\Rightarrow Q_1$ ស្ថិតនៅចន្លោះ 10 – 15 យើងបាន:

$$Q_1 = 10 + \frac{59.75 - 18}{72} \times 5 = 12.89$$

ដូចនេះ: $\boxed{Q_1 = 12.89mm}$

$+ \ Q_3 = L + \frac{\frac{3}{4}n - f^{\uparrow}}{f} \times i$ ដែល $\frac{3}{4}n = 179.25$

$\Rightarrow Q_3$ ស្ថិតរនៅថ្នាក់ 20 – 25

$$\Rightarrow Q_3 = 20 + \frac{179.25 - 105}{90} \times 5 = 24.125$$

ដូចនេះ: $\boxed{Q_3 = 24.125}$

$+ \ D_1 = L + \frac{\frac{1}{10}n - f^{\uparrow}}{f} \times i$ ដែល $\frac{1}{10}n = 23.9$

$\Rightarrow D_1$ ស្ថិតនៅថ្នាក់ 10 – 15

$$\Rightarrow D_1 = 10 + \frac{23.9 - 18}{72} \times 5 = 10.40mm$$

ដូចនេះ: $\boxed{D_1 = 10.40mm}$

7. គណនមេដ្យាន និង $L_{28}$

បង្កើតតារាងប្រេកង់កើន:

| ចំនួនសៀវភៅ | ចំនួនថ្ងៃ | $f^{\uparrow}$ |
|---|---|---|
| 30-35 | 4 | 4 |
| 35-40 | 6 | 10 |
| 40-45 | 10 | 20 |
| 45-50 | 13 | 33 |
| 50 55 | 5 | 38 |
| 55-60 | 2 | 40 |

យើងបាន: $(n=40)$

មេដ្យាន $= L + \dfrac{\frac{1}{2}n - f^{\uparrow}}{f} \times i$

យើងដឹងថា មេដ្យាន = តម្លៃតួទី $\frac{1}{2}n$ = តម្លៃតួទី 20

ដូច្នេះ មេដ្យានស្ថិតនៅថ្នាក់ 40 – 45

អោយ មេដ្យាន $= 40 + \dfrac{20+10}{10} \times 5 = 45$

ដូចនេះ **មេដ្យានស្មើនឹង 45**

$$L_{28} = L + \frac{\frac{28}{100}n - f^{\uparrow}}{f} \times i$$

យើងដឹងថា $L_{28}$ = តម្លៃតួទី $\dfrac{28}{100}n$ = តម្លៃតួទី 11.2

ដូច្នេះ $L_{28}$ ស្ថិតនៅថ្នាក់ 40 -45

$$\Rightarrow L_{28} = 40 + \frac{11.2-10}{10} \times 5 = 40.6$$

ដូចនេះ $\boxed{L_{28} = 40.6}$

<u>មេរៀនទី២</u>

## រង្វាស់នៃគំលាត

### <u>លំហាត់</u>

1. គណនាវ៉ង់ និងចន្លោះអាំងទែកាទីលនៃសំណុំទិន្នន័យខាងក្រោម៖

ក. 5 16 9 8 6 10 12 10 8 6

ខ.

| x | 3 | 4 | 5 | 6 | 7 | 8 | 9 |
|---|---|---|---|---|---|---|---|
| f | 5 | 2 | 7 | 9 | 4 | 10 | 5 |

2. ប្រាក់ចំណូលប្រចាំសប្តាហ៍(គិតជាដុល្លារ) របស់អ្នកដឹកនាំថ្នាក់កណ្តាលក្នុងក្រុមហ៊ុនមួយមាន 52 56 58 65 68 65 75 70។ ដោយសន្មតថាទិន្នន័យទាំងនេះជាសកលស្ថិតិ 1

ក. គណនាវ៉ង់ ខ. គណនាវ៉ារ្យង់សកលស្ថិតិ និងគំលាតស្តង់ដាសកលស្ថិតិ។

3. ពូសែ និងពូសុខជាឈ្មួញទិញជ្រូកដូចគ្នា។ ឈ្មួញទាំងពីរទិញជ្រូកម្នាក់ 10 ក្បាល ដែលជ្រូកនីមួយៗមានម៉ាស

| ម៉ាសជ្រូកពូសែ (គិតជាKg) | 70 | 92 | 102 | 98 | 105 | 35 | 39 | 39 | 40 | 60 |
|---|---|---|---|---|---|---|---|---|---|---|
| ម៉ាសជ្រូកពូសុខ (គិតជាKg) | 63 | 63 | 65 | 71 | 72 | 74 | 40 | 58 | 80 | 94 |

ក. គណនាវ៉ារ្យង់ ( ស្ថិតិសកល )

ខ. តើឈ្មួញមួយណាទិញជ្រូកបានម៉ាសស្មើសាច់ជាង ?

4. គេមានទិន្នន័យ $a$ $b$ 8 5 7 (ជាស្ថិតិសកល) ដែលមានតម្លៃមធ្យមស្មើនឹង 6 និងវ៉ារ្យង់ស្មើនឹង 2 ។ គណនាតំលៃ $a$ និង $b$ បើ $a>b$ ។

5. បំណែងចែកប្រេកង់ខាងក្រោម ជាបំលែងចែកម៉ាស (kg) ជ្រូកចំនួន 40 ក្បាលក្នុងកសិដ្ឋានមួយ

| ម៉ាស (kg) | 20-30 | 30-40 | 40-50 | 50-60 | 60-70 |
|---|---|---|---|---|---|
| ចំនួនជ្រូក $f_i$ | 5 | [illegible] | 10 | 11 | 6 |

ក. គណនាវ៉ង់ ខ. គណនាមធ្យម គ. គណនាគំលាតស្តង់ដា

## ដំណោះស្រាយ

1. គណនាវ៉ង់ និងចន្លោះអាំងទែកាទីលៈ

ក. 5 16 9 8 6 10 12 10 8 6

រៀបទិន្នន័យតាមលំដាប់កើនៈ

5 6 6 8 8 9 10 10 12 16

យើងបានៈ វ៉ង់ $\boxed{=16-5=11}$

+ $I=Q_3-Q_1$ ដែល $n=10$

$Q_3=$ តម្លៃតួទី $\frac{3}{4}(n+1)=$ តម្លៃទី 8.25

$$\Rightarrow Q_3 = \frac{10+12}{2} = 11$$

$Q_1 =$ តម្លៃតួទី $\frac{1}{4}(10+1) =$ តម្លៃតួទី 2.75

$$\Rightarrow Q_1 = \frac{6+6}{2} = 6$$

យើងបាន: $\boxed{I = 11-6 = 5}$

ខ. បង្កើតតារាងប្រេកង់កើន:

| x | f | f ↗ |
|---|---|---|
| 3 | 5 | 5 |
| 4 | 2 | 7 |
| 5 | 7 | 14 |
| 6 | 9 | 23 |
| 7 | 4 | 27 |
| 8 | 10 | 37 |
| 9 | 5 | 42 |

+ វ៉ $= 9-3 = 6$

+ $I = Q_3 - Q_1$ ដែល

$Q_3 =$ តម្លៃតួទី $\frac{3}{4}(42+1) =$ តម្លៃតួទី32.25

ដូច្នេះ $\boxed{Q_3 = 8}$

$Q_1 =$ តម្លៃតួទី $\frac{1}{4}(42+1) =$ តម្លៃតួទី 10.75

ដូច្នេះ $\boxed{Q_1 = 5}$

$\Rightarrow I = 8-5 = 3$

2.ក. វ៉ង់ $= 75-52 = 23$

ខ. តាមរូបមន្ត $\sigma^2 = \frac{\sum (Xi-\mu)^2}{N}$ ដែល

$$\mu = \frac{\sum Xi}{N} = \frac{52+56+58+65+68+65+75+70}{8}$$

$= 63.6$

| $Xi - \mu$ | $(Xi - \mu)^2$ |
|---|---|
| 52-63.5=-11.6 | 134.56 |
| 56-63.6=-7.6 | 57.76 |
| 58-63.6=-5.6 | 31.36 |
| 65-63.6=1.4 | 1.96 |
| 68-63.6=4.4 | 19.36 |
| 65-63.6=1.4 | 1.36 |
| 75-63.6=11.4 | 129.96 |
| 70-63.6=6.4 | 40.96 |
| | $\sum (Xi-\mu)^2 = 417.68$ |

ដូចនេះ $\boxed{\sigma^2 = \frac{417.68}{8} = 52.21}$

$\Rightarrow \sigma = \sqrt{52.21} = 7.22$

3. ក. គណនាវ៉ារ្យង់ ( ស្ថិតិសកល )

តាមរូបមន្ត:

$$\sigma^2 = \frac{\sum (Xi-\mu)^2}{N}$$

ដែល $\mu_2 = \frac{\sum Xi}{N} = 68$

$$\mu_1 = \frac{\sum Xi}{N} = 68$$

| ជ្រូកសុខ(kg) | $X_i-\mu_1$ | $(X_i-\mu_1)^2$ | ជ្រូកវែង | $X_i-\mu_2$ | $(X_i-\mu_2)^2$ |
|---|---|---|---|---|---|
| 63 | -5 | 25 | 70 | 2 | 4 |
| 63 | -5 | 25 | 92 | 24 | 576 |
| 65 | -3 | 9 | 102 | 34 | 1156 |
| 71 | 3 | 9 | 98 | 30 | 900 |
| 72 | 4 | 16 | 105 | 37 | 1369 |
| 74 | 6 | 36 | 35 | -33 | 1089 |
| 40 | -28 | 784 | 39 | -29 | 841 |
| 58 | -10 | 100 | 39 | -29 | 841 |
| 80 | 12 | 144 | 40 | -28 | 784 |
| 94 | 26 | 676 | 60 | -8 | 64 |
| | | $\sum(X_i-\mu_1)^2=1824$ | | | $\sum(X_i-\mu_2)^2=7624$ |

យើងបាន: $\sigma_1^2=\dfrac{1824}{10}=182.4$

$$\sigma_2^2=\frac{7624}{10}=762.4$$

ខ. ដោយ $\sigma_2^2<\sigma_2^2$ នោះពូសុខទិញជ្រូកបានម៉ាស ស្មើសាច់ជាង ,

4. គណនាតំលៃ $a$ និង $b$

យើងមាន: $\mu=\dfrac{a+b+8+5+7}{5}$ តែ $\mu=6$

$$\Rightarrow \frac{a+b+20}{50}=6 \Leftrightarrow a+b=10 \quad (1)$$

ម្យ៉ាងទៀត $\dfrac{\sum X_i^2}{N}-\mu^2=\sigma^2$ តែ $\sigma^2=2$

$$\Rightarrow \frac{a^2+b^2+8^2+5^2+7^2}{5}-6^2=2$$

$$\Rightarrow \frac{a^2+b^2+138-180}{5}=2$$

$$\Rightarrow a^2+b^2-42=10 \Leftrightarrow a^2+b^2=52 \quad (2)$$

(1) គេទាញបាន: $a=10-b$ ជំនួស (2) គេបាន:

$$(10-b)^2+b^2=52 \Leftrightarrow 2b^2-20b+48=0$$

$$\Rightarrow b^2-10b+24=0$$

$$\Delta'=25-24=1 \Rightarrow b_1=6, b_2=4$$

ចំពោះ: $b=6 \Rightarrow a=4$

ចំពោះ: $b=4 \Rightarrow a=6$

ដោយ $a>b$ នោះ: $\boxed{a=6,\ b=4}$

. ការវង់ $=70-20=50$

ខ. គណនាមធ្យម $\overline{X}$

| [illegible](kg) | $X_i - \mu_1$ | $(X_i - \mu_1)^2$ | [illegible] | $X_i - \mu$ | $(X_i - \mu)^2$ |
|---|---|---|---|---|---|
| 63 | -5 | 25 | 70 | 2 | 4 |
| 63 | -5 | 25 | 92 | 24 | 576 |
| 65 | -3 | 9 | 102 | 34 | 1156 |
| 71 | 3 | 9 | 96 | 30 | 900 |
| 72 | 4 | 16 | 105 | 37 | 1369 |
| 74 | 6 | 36 | 75 | -33 | 1089 |
| 40 | -28 | 784 | 39 | -29 | 841 |
| 58 | -10 | 100 | 39 | -29 | 841 |
| 80 | 12 | 144 | 40 | -28 | 784 |
| 94 | 26 | 676 | 60 | -8 | 64 |
| | | $\sum(X_i-\mu_1)^2 = 182$[illegible] | | | $\sum(X_i-\mu_1)^2 = 7624$ |

$$\overline{X} = \frac{\sum f_i X_i}{\sum f_i} = \frac{1850}{40} = 46.25$$

គ. គណនាគំលាតស្តង់ដារៈ

$$S = \sqrt{\frac{\sum f_i X_i^2}{\sum f_i} - \overline{X}^2} = \sqrt{\frac{91800}{40} - (46.25)^2}$$

$$= \sqrt{2295 - 2139.0625} = \sqrt{155.93}$$

$$\boxed{S = 12.49}$$

មេរៀនទី៣

## បំរែលងបែកនរ៉ម៉ាល់

### លំហាត់

1. បំរែលងចែកនរ៉ម៉ាល់មួយមានមធ្យមស្មើនឹង 80 និងមានគំលាតស្មើនឹង 14 ។

ក. គណនាជាភាគរយនៃទិន្នន័យដែលស្ថិតនៅ

ចន្លោះ 75 និង 90 ។

ខ. គណនាជាភាគរយនៃទិន្នន័យដែលតិចជាង 75

គ. គណនាជាភាគរយនៃទិន្នន័យដែលនៅចន្លោះ 55និង 70

2. បើ $z$ តាងបំណែងចែកន័រម៉ាល់ ដែលមានមធ្យមស្មើនឹង 0 និងគំលាតស្តង់ដាស្មើនឹង 1 ។

គណនាតម្លៃ $a$ បើ

ក. ភាគរយដែល $(z < a) = 96.93\%$

ខ. ភាគរយដែល $(z > a) = 88.49\%$ ។

3. កម្ពស់ក្មេងប្រុសមួយក្រុមដែលមានអាយុ15 ឆ្នាំជាបំណែងចែកន័រម៉ាល់មានមធ្យមស្មើនឹង $150.3cm$ និងគំលាតស្តង់ដាស្មើនឹង $5cm$ ។ គណនាជាភាគរយដែលគេជ្រើសរើសដោយចៃដន្យបានក្មេងម្នាក់កម្ពស់: ក. តិចជាង $153cm$

ខ. ច្រើនជាង $158cm$ គ. នៅចន្លោះ $147cm$ និង $149cm$

ឃ. នៅចន្លោះ $150cm$ និង $158cm$ ។

4. កម្ពស់ដើមផ្កាក្នុងសួនមួយកន្លែងជាបំណែងចែកន័រម៉ាល់ដែលមានមធ្យមស្មើនឹង $\mu$ និងមានគំលាតស្មើនឹង $6cm$ ។ គេដឹងថាមាន 4.78% នៃដើមផ្កាទាំងអស់មានកម្ពស់ខ្ពស់ ជាង $82cm$ ។ គណនាតម្លៃនៃ $\mu$ ។

## ដំណោះស្រាយ

1. បំណែងចែកនរម៉ាល់មួយមាន $\mu = 80$ និង $\sigma = 14$ ។

ក. គណនាជាភាគរយនៃទិន្នន័យដែលស្ថិតនៅចន្លោះ 75និង90

ភាគរយដែល $(75 < X < 90) =$

ភាគរយដែល$\left(\frac{75-80}{14} < Z < \frac{90-80}{14}\right)$

$=$ភាគរយដែល $(-0.36 < Z < 0.71)$

$= 0.1406 + 0.2611 = 0.4017 = \boxed{40.17\%}$

ខ. គណនាជាភាគរយនៃទិន្នន័យដែលតិចជាង 75

ភាគរយដែល $(X < 75)$ = ភាគរយដែល $(Z < -0.36)$

$= 0.5 - 0.1406 = 0.3594 = \boxed{35.94\%}$

គ. គណនាជាភាគរយនៃទិន្នន័យដែលស្ថិតនៅចន្លោះ 55និង70

ភាគរយដែល $(55 < X < 70) =$ ភាគរយដែល

$\left(\frac{55-80}{14} < Z < \frac{70-80}{14}\right) =$ ភាគរយដែល

$(-0.79 < Z < -0.2611) = 0.4633 - 0.2611$

$= 0.2022 = \boxed{20.22\%}$

2. គណនាតម្លៃ $a$ បើ:

ក. ភាគរយដែល

$(z<a)=96.93\% \Leftrightarrow 0.5+a=0.9693$

$\Leftrightarrow a=0.9693-0.5=0.4693$

តាមតារាងក្រលាផ្ទៃស្ថិតនៅក្រោមខ្សែកោងន័រម៉ាល់

គេបាន $\boxed{a=1.87}$

ខ. ភាគរយដែល $(z>a)=88.49\%$

$\Leftrightarrow 0.5-a=0.8849 \Leftrightarrow -a=0.3849$

តាមតារាងក្រលាផ្ទៃស្ថិតនៅក្រោមខ្សែកោងន័រម៉ាល់

គេបាន $-a=1.2$ រឺ $\boxed{a=-1.2}$

3. គណនាជាភាគរយដែលគេជ្រើសរើសដោយចៃដន្យបានក្មេងប្រុសម្នាក់កំពស់:

ក. តិចជាង $153cm$ យើងមាន:

ភាគរយដែល $(z<0.153)=$ ភាគរយដែល

$$\left(z>\frac{153-150.3}{5}\right)$$

$=$ ភាគរយដែល $(z<0.54)=0.5+0.2054$

$=0.7054=\boxed{70.54\%}$

ខ. ច្រើនជាង $158cm$ យើងមាន:

ភាគរយដែល $(z > 158)$ = ភាគរយដែល

$\left(z < \frac{158-150.3}{5}\right)$ = ភាគរយដែល $(z > 1.54)$

$= 0.5 - 0.4382 = 0.0618 = 6.18\%$

គ. នៅចន្លោះ $147cm$ និង $149.5cm$

ភាគរយដែល $(147 < X < 149.5)$

= ភាគរយដែល $\left(\frac{147-150.3}{5} < z < \frac{149.5-150.3}{5}\right)$

= ភាគរយដែល $(-0.66 < X < -0.16)$

$= 0.2454 - 0.0636 = 0.1818 = 18.18\%$

ឃ. នៅចន្លោះ $150cm$ និង $158cm$

ភាគរយដែល $(150 < X < 158)$

= ភាគរយដែល $\left(\frac{150-150.3}{5} < z < \frac{158-150.3}{5}\right)$

= ភាគរយដែល $(-0.06 < z < 1.54)$

$= 0.4382 + 0.0239 = 0.4621 = 46.21\%$

4. គណនាតម្លៃនៃ $\mu$ យើងមាន:

ភាគរយដែល $\left(z > \frac{82-\mu}{6}\right) = 4.78\%$

$$\Leftrightarrow 0.5-\frac{82-\mu}{6}=0.0478 \Leftrightarrow 0.5-0.0478$$

